សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា

# ទេសន្តរប្រវេសន៍

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **នុត វណ្ណៈ**

សាស្ត្រាចារ្យណែនាំ

លោក **ម៉ៅ បុណ្ណា**

ថ្នាក់ **បរិញ្ញាបត្រជាន់ខ្ពស់ នីតិសាស្ត្រ**

ជំនាញ **នីតិឯកជន** ជំនាន់១០

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេររបាយការណ៍ ២០១៤

**រក្សាសិទ្ធិដោយ** Khmer Famous

# សេចក្តីថ្លែងអំណរគុណ

ភាពជោគជ័យក្នុងការសរសេររបាយការណ៍បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នីតិសាស្ត្រ ជំនាញនីតិឯកជន នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានជាស្ពាពររបស់ខ្ញុំបាទគឺអាស្រ័យដោយមានការជួយជ្រោមជ្រែងយ៉ាងច្រើនពីសំណាក់:

- លោកឪពុក **សំ ឧុទ្ធី** និងអ្នកម្តាយ **អ៊ុំ ចាន់នី** ដែលលោកបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មាន ប្រៀនប្រដៅ ផ្តល់ធនធាន សម្រាប់ការសិក្សារៀនសូត្រ តាំងតែពីថ្នាក់មត្តេយ្យរហូតដល់ថ្នាក់ឧត្តមសិក្សា។ ដោយសារតែគុណូបការៈ របស់លោកអ្នកមានគុណទាំងពីរ ទើបធ្វើឱ្យខ្ញុំបានរៀនសូត្រ និងមានចំណេះវិជ្ជាដ៏ថ្លៃថ្លានេះ។

- លោកយាយ **ចាយ ទ៉ា** លោកឪពុកធំ **អ៊ុំ តារា** លោកឪពុកធំ **អ៊ុំ សុវណ្ណា** ម្តាយមីង **អ៊ុំ ចាន់សាលី** និងម្តាយមីង **អ៊ុំ ចាន់ណាវី** ដែលបានខិតខំលើកទឹកចិត្ត ផ្តល់ថវិកា និង ទូន្មានប្រៀនប្រដៅ ខ្ញុំបាទគ្រប់ពេលវេលា។

- លោកឪពុកមា **មិន ណារ៉ុំ** ដែលបានជំរុញ លើកទឹកចិត្ត និងផ្តល់ដំបូន្មានល្អៗ ឱ្យខ្ញុំបាទជ្រើសរើសផ្នែកនីតិសាស្ត្រ ដើម្បីសិក្សាតាំងពីចាប់ផ្តើម រហូតដល់ខ្ញុំបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកនីតិសាស្ត្រ។

ទន្ទឹមនឹងនេះដែរខ្ញុំក៏សូមសម្តែងអំណរគុណ លោកគ្រូអ្នកគ្រូ ព្រមទាំងសាស្ត្រាចារ្យ ទាំងអស់ដែលបានលះបង់កម្លាំងកាយ កម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃ ជួយបង្ហាត់បង្ហាញ និងផ្តល់ចំណេះដឹងដល់រូបខ្ញុំ តាំងពីវ័យកុមារ រហូតដល់បច្ចុប្បន្ន។ ដោយសារតែគុណូបការៈ របស់លោកអ្នកទាំងអស់នេះហើយ ទើបខ្ញុំមានចំណេះដឹង អាចធ្វើការសិក្សាស្រាវជ្រាវ ស្វែងយល់ពីបញ្ហានានានៅក្នុងសង្គម និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអភិវឌ្ឍន៍ខ្លួនឱ្យក្លាយជាពលរដ្ឋដ៏ល្អ និងចូលរួមអភិវឌ្ឍប្រទេសជាតិឱ្យបានរីកចម្រើន ។

លើសពីនេះទៅទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះលោកសាស្ត្រាចារ្យ **ម៉ៅ បុណ្ណា** ដែលបានធ្វើជាសាស្ត្រចារ្យណែនាំខ្ញុំបាទធ្វើរបាយការណ៍ស្រាវជ្រាវ បញ្ចាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងបានលះបង់ពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្ហាញ ផ្តល់ដំបូន្មាន និងយុទ្ធសាស្ត្រផ្សេងៗក្នុងការស្វែងរកឯកសារ។

ខ្ញុំសូមគោរពជូនពរ ដល់លោកអ្នកមានគុណទាំងអស់ ឱ្យជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើនគ្រប់ពេលវេលា។

# ឧទ្ទិសស្នាដៃ

ខ្ញុំបាទសូមឧទ្ទិសស្នាដៃ ដែលកើតឡើងពីការសិក្សាស្រាវជ្រាវ លើប្រធានបទស្តីពី " **ទេសន្តរប្រវេសន៍** " នេះ ជូនអ្នកមានគុណដូចខាងក្រោមៈ

-លោកតា **អ៊ុំ ជ្រូក** លោកតា **មិន សេខ** និងលោកយាយ **នខ ឈួន** ដែលបានចែកឋាន និងជាអ្នកមានគុណបន្ទាប់ពីលោកឪពុកអ្នកម្តាយបង្កើតរបស់ខ្ញុំបាទ ដែលធ្លាប់បានផ្តល់ការលើទឹកចិត្ត និងថវិកា ចិញ្ចឹមបីបាច់ថែរក្សា ឱ្យខ្ញុំបាទ ខិតខំរៀនសូត្រ សន្សំចំណេះដឹងគ្រប់បែបយ៉ាង រហូតដល់ខ្ញុំបាទទទួលលទ្ធផល ដ៏ល្អប្រសើរ។ ប៉ុន្តែ គួរឱ្យសោកស្តាយ ដែលលោកអ្នកមានគុណមិនបាននៅមើលឃើញលទ្ធផលដ៏ល្អ និងភាពជោគជ័យរបស់ចៅ។

-ប្រជារាស្ត្រខ្មែរគ្រប់ជំនាន់ និងគ្រប់រូបដែលបានខិតខំធ្វើពលិកម្ម ក្នុងការការពារប្រទេសជាតិ និងអភិវឌ្ឍន៍មាតុប្រទេសជាតិខ្មែរយើង ឱ្យបានរស់រានរហូតដល់ពេលបច្ចុប្បន្ន ផុតពីការឈ្លានពានរបស់ពួកបរទេស។

-អ្នកប្រាជ្ញ បញ្ញាវន្តខ្មែរដែលបានបូជាកម្លាំងកាយចិត្ត និងទ្រព្យធនក្នុងការការពារ ចងក្រងឯកសារ អក្សរសាស្ត្រ ទុកជាមរតកសម្រាប់កូនខ្មែរជំនាន់ក្រោយ។

សូមមនសិការជាតិខ្មែរ ស្ថិតនៅជាប់ជានិច្ច ក្នុងដួងព្រលឹងប្រជារាស្ត្រខ្មែរ!

សូមឱ្យព្រះរាជាណាចក្រកម្ពុជា មានសន្តិភាព សុវត្ថិភាពជាយូរអង្វែងដរាបរៀងទៅ!

សូមឱ្យមានឯករាជ្យជាតិខ្មែរ បូរណភាពទឹកដី កាន់តែរឹងមាំពីមួយថ្ងៃទៅមួយថ្ងៃ!

សូមឱ្យកូនខ្មែរគ្រប់រូប និងគ្រប់សម័យកាលខិតខំរៀនសូត្រ ដើម្បីអនាគតអ្នក គ្រួសារអ្នក និងមាតុភាពជាតិរបស់យើងទាំងអស់គ្នា!

# មូលវិចារណ៍

ខ្ញុំសូមកោតសរសើរនិស្សិត **នុត ខណ្ណា:** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកនីតិសាស្រ្ត ជំនាញនីតិឯកជន ជំនាន់១០ ជំហាន២ ដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច បានតស៊ូ ព្យាយាម យ៉ាងយកចិត្តទុកដាក់ក្នុងការសិក្សាស្រាវជ្រាវ លើប្រធានបទ **ទេសន្តរប្រវេសន៍** ។

និស្សិតរូបនេះបានកំណត់យក និងធ្វើការសិក្សាស្រាវជ្រាវប្រធានបទខាងលើនេះ ដោយសារតែនិស្សិតយល់ឃើញថា ជាប្រធានបទមានសារសំខាន់សម្រាប់ធ្វើការស្វែងយល់ អំពីការធ្វើទេសន្តរប្រវេសន៍យ៉ាងច្រើនកុះកររបស់ប្រជាពលរដ្ឋខ្មែរ ពីតំបន់ជនបទ ទៅទីប្រជុំជន នៅក្នុងប្រទេសកម្ពុជា និងការធ្វើទេសន្តរប្រវេសន៍ទៅកាន់បរទេសរបស់ប្រជាពលរដ្ឋខ្មែរ។

ការវិភាគទាំងឡាយនៅក្នុងឯកសារនេះ គឺជាស្នាដៃ និងជាគំនិតផ្ទាល់ខ្លួនរបស់និស្សិតដែលបានសិក្សាស្រាវជ្រាវកន្លងមក។

ការសិក្សាស្រាវជ្រាវនេះ គឺជាលទ្ធផលនៃរបកគំហើញបែបវិទ្យាសាស្រ្តមួយ ក្នុងបច្ចេកទេសសិក្សាស្រាវជ្រាវលើជំនាញវិទ្យាសាស្រ្តសង្គម និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកនីតិសាស្រ្ត ជំនាញនីតឯកជន ដែលជាបទពិសោធន៍ដ៏សំខាន់ និងសម្រាប់ការចែករំលែកដល់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយៗ ទៀត ដើម្បីស្រាវជ្រាវ វិភាគ និងស្វែងយល់។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី……….ខែ…….ឆ្នាំ២០១៤

**ហត្ថលេខា**

**សាស្ត្រាចារ្យ ម៉ៅ បុណ្ណា**

# អំណះអំណាង

ខ្ញុំបាទឈ្មោះ **នុត វណ្ណៈ** អក្សរឡាតាំង NUTH VANNAK ភេទប្រុស កើតថ្ងៃទី២៣ ខែវិច្ឆកា ឆ្នាំ១៩៨៧ សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ អាសយដ្ឋានបច្ចុប្បន្ននៅ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នីតិសាស្ត្រ ជំនាញនីតិឯកជន ជំនាន់១០ ជំហាន២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច រាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា សូមធ្វើការធានាអះអាង និងទទួលខុសត្រូវ ទាំងស្រុងលើខ្លឹមសារ នៃឯកសារនេះ ដែលពិតជាស្នាដៃ នៃការសិក្សាស្រាវជ្រាវរបស់ខ្ញុំបាទពិត ប្រាកដមែន។

រាជធានីភ្នំពេញ.ថ្ងៃទី..........ខែ.........ឆ្នាំ២០១៤

ហត្ថលេខា

**នុត វណ្ណៈ**

# អារម្ភកថា

ក្រោយពីបានសិក្សាស្រាវជ្រាវ នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកនីតិសាស្ត្រ ជំនាញនីតិឯកជន អស់រយៈពេលពីរឆ្នាំ និងដើម្បីឈានទៅបញ្ចប់ការសិក្សាជាស្ថាពរ និងអាចទទួលបានសញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ ប្រកបដោយជោគជ័យ សាកលវិទ្យាល័យ បានតម្រូវឱ្យនិស្សិតម្នាក់ៗ ជ្រើសរើសប្រធានបទមួយ ដើម្បីធ្វើការសិក្សាស្រាវជ្រាវ សរសេរជារបាយការណ៍ស្រាវជ្រាវ ឬសរសេរជានិក្ខេបបទ ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ។

ដូច្នេះ ខ្ញុំបាទបានសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី “ **ទេសន្តរប្រវេសន៍** ” ក្នុងគោលបំណងស្វែងយល់ឱ្យច្បាស់លាស់ ពីមូលហេតុ លក្ខខណ្ឌ និងមូលហេតុផ្សេងៗ ទៀតដែលជំរុញឱ្យប្រជាពលរដ្ឋខ្មែរជាច្រើន បានបង្ខំចិត្តចាកចេញពីភូមិកំណើត ឃ្លាតឆ្ងាយពីលោកឪពុកអ្នកម្តាយជាទីស្រឡាញ់ បែកឆ្ងាយពីប្តីប្រពន្ធ និងបងប្អូនប្រុសស្រី ធ្វើអន្តោប្រវេសន៍ពីតំបន់ជនបទ ទៅកាន់តំបន់ទីក្រុង ដើម្បីស្វែងរកការងារធ្វើ។ អ្នកខ្លះទៀត បានឈានទៅដល់ការធ្វើអន្តោប្រវេសន៍ស្របច្បាប់ និងខុសច្បាប់ទៅប្រទេសផ្សេងទៀត ដើម្បីអាចទទួលបានការងារ និងប្រាក់ខែសមរម្យសម្រាប់ផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួន ឱ្យបានល្អប្រសើរជាងមុន និងសល់មួយចំណែកទៀត អាចផ្ញើជូនក្រុមគ្រួសារនៅស្រុកកំណើត។ ពលរដ្ឋខ្មែរភាគច្រើន បានធ្វើអន្តោប្រវេសន៍ទៅធ្វើការនៅប្រទេសមួយចំនួនដូចជា៖ ប្រទេសថៃ កូរ៉េ និង ម៉ាឡេស៊ី ជាដើម។ល។

ជាចុងក្រោយខ្ញុំបាទសង្ឃឹមថា ឯកសាររបាយការណ៍ស្រាជ្រាវនេះ អាចមានប្រយោជន៍សម្រាប់និស្សិតច្បាប់ជំនាន់ក្រោយៗ និងបុគ្គលផ្សេងទៀត ដែលមានបំណងស្វែងរកឯកសារទាក់ទងនឹងទេសន្តរប្រវេសន៍ យកមកធ្វើការសិក្សារៀនសូត្រ និងស្រាវជ្រាវ។

# មាតិកា

ទំព័រ

**សេចក្ដីថ្លែងអំណរគុណ**.............................................................................................i

**ឧទ្ទិសស្លាដៃ**........................................................................................................ii

**មូលវិចារណ៍** ....................................................................................................... iii

**អំណះអំណាង**.......................................................................................................iv

**អារម្ភកថា** ............................................................................................................v

**មាតិកា** ...............................................................................................................vi

**បញ្ជីអក្សរកាត់** ....................................................................................................viii

**បញ្ជីតារាង**..........................................................................................................ix

**បញ្ជីរូប**...............................................................................................................x

**សេចក្ដីផ្ដើម** ......................................................................................................... ១

**ជំពូកទី១**: **ទេសន្តរប្រវេសន៍ជាតិ**.................................................................................. ៣

១.១. មូលហេតុនៃការធ្វើទេសន្តរប្រវេសន៍នៅកម្ពុជា................................................. ៣

១.២. ទីកន្លែងគោលដៅការងារនៅទីប្រជុំជន ............................................................. ៦

១.៣. សារៈសំខាន់នៃយេនឌ័រ សម្រាប់ទេសន្តរប្រវេសន៍ការងារ................................ ៧

១.៤. ផលប៉ះពាល់លើសុខភាពពីការធ្វើទេសន្តរប្រវេសន៍ ពីទីជនបទ ទៅទីប្រជុំជន..... ៩

**ជំពូកទី២: ទេសន្តរប្រវេសន៍អន្តរជាតិ** ........ ១០

២.១. មូលហេតុនៃការធ្វើទេសន្តរប្រវេសន៍ទៅបរទេស ........ ១១

២.២. ការធ្វើទេសន្តរប្រវេសន៍ទៅប្រទេសម៉ាឡេស៊ី ........ ១៣

២.៣. ការធ្វើទេសន្តរប្រវេសន៍ទៅប្រទេសថៃ ........ ១៥

២.៤. ការធ្វើទេសន្តរប្រវេសន៍ទៅសាធារណៈរដ្ឋកូរ៉េខាងត្បូង ........ ១៧

**ជំពូកទី៣: ប្រាក់បញ្ញើត្រឡប់** ........ ១៩

៣.១. លំហូរប្រាក់បញ្ញើត្រឡប់ និងអត្ថប្រយោជន៍នៃទេសន្តរប្រវេសន៍អន្តរជាតិ ........ ១៩

៣.២. លំហូរប្រាក់បញ្ញើត្រឡប់ និងអត្ថប្រយោជន៍នៃទេសន្តរប្រវេសន៍ក្នុងប្រទេស ........ ២២

**សេចក្តីសន្និដ្ឋាន** ........ ២៥

**អនុសាសន៍** ........ ២៦

**គន្ថនិទ្ទេស** ........ ២៨

**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

- **RGC** = Royal Government of Cambodia រាជរដ្ឋាភិបាលកម្ពុជា
- **FDI** = Foreign Direct Investment វិនិយោគបរទេសផ្ទាល់
- **NPRS** = National Poverty Reduction Strategy យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ
- **CI** = Certificate of Identity ប័ណ្ណសម្គាល់ខ្លួន
- **MoLVT** = Ministry of Labor and Vocational Training ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- **GDP** = Gross Domestic Product ផលិតផលសរុបក្នុងស្រុក
- **CDRI** = Cambodia Development Resource Institute វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

# បញ្ជីតារាង

**ទំព័រ**


**តារាងទី១:** ការបែងចែកទេសន្តរប្រវេសន៍នៅកម្ពុជា១៩៩៨ និង ២០០៨………………………………....៣

**តារាងទី២:** មូលហេតុនៃការធ្វើទេសន្តរប្រវេសន៍នៅកម្ពុជា១៩៩៨ និង ២០០៨…………………………..៤

**តារាងទី៣:** ការបែងចែកទេសន្តរប្រវេសន៍ជនបទ និងទីប្រជុំជននៅកម្ពុជា១៩៩៨ និង ២០០៨…...៥

**តារាងទី៤:** ភាគរយនៃការបែងចែកទេសន្តរប្រវេសន៍នៅកម្ពុជា១៩៩៨ និង ២០០៨………………….៥

**តារាងទី៥:** ចំនួនពលករទេសន្តរប្រវេសន៍កម្ពុជាធ្វើការនៅប្រទេសម៉ាឡេស៊ី…………………………..១៤

**តារាងទី៦:** ចំនួនពលករទេសន្តរប្រវេសន៍កម្ពុជាធ្វើការនៅប្រទេសថៃ…………………………………..១៥

**តារាងទី៧:** ចំនួនពលករទេសន្តរប្រវេសន៍កម្ពុជាធ្វើការនៅប្រទេសកូរ៉េខាងត្បូង……………………..១៨

**តារាងទី៨:** បណ្តាញប្រាក់បញ្ញើត្រឡប់សម្រាប់ការធ្វើទេសន្តរប្រវេសន៍ជនបទ និងទីប្រជុំជន….២២

# បញ្ជីរូប

**ទំព័រ**

**រូបភាពទី ១៖** គោលដៅការងារសម្រាប់ជនទេសន្តរប្រវេសន៍វ័យជំទង់ពីជនបទ ទៅទីប្រជុំជន.......៦

**រូបភាពទី២៖** ១០ប្រទេសដែលទទួលបានប្រាក់បញ្ញើត្រឡប់ច្រើនជាងគេ…………………………..១៩

**រូបភាពទី៣៖** ប្រព័ន្ធផ្ទេរប្រាក់ពីប្រទេសថៃមកកម្ពុជា..............................................................២០

**រូបភាពទី៤៖** ១០ប្រទេសដែលទទួលបានប្រាក់បញ្ញើត្រឡប់ច្រើនជាងគេ..................................២១

**រូបភាពទី៥៖** ការផ្លាស់ប្តូរលក្ខខណ្ឌហិរញ្ញវត្ថុរបស់ក្រុមគ្រួសារពលករទេសន្តរប្រវេសន៍.............២៤

# សេចក្តីផ្តើម

ពលករទេសន្តរប្រវេសន៍ ដើរតួនាទីយ៉ាងសំខាន់ ក្នុងការជួយផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ និងក្រុមគ្រួសារ ឱ្យមានកម្រិតជីវភាពកាន់តែល្អប្រសើរជាងមុន ក៏ដូចជាជួយក្នុងការអភិវឌ្ឍន៍សង្គម និងប្រទេសជាតិឱ្យមានការរីកចម្រើនផងដែរ។ ម្យ៉ាងវិញទៀត ប្រាក់ចំណូលដែលពលករទេសន្តរប្រវេសន៍ ផ្ញើត្រឡប់មកឱ្យក្រុមគ្រួសាររបស់ពួកគេ គឺជាប្រភពនៃលំហូរហិរញ្ញវត្ថុដ៏ប្រសើរសម្រាប់សេដ្ឋកិច្ចជាតិ និងអាចកាត់បន្ថយភាពក្រីក្រ នៅក្នុងប្រទេសបានថែមមួយកម្រិតទៀត។

ប៉ុន្តែ រយៈពេលប៉ុន្មានឆ្នាំនេះ មានបញ្ហាជាច្រើនកើតមានឡើងចំពោះប្រជាពលរដ្ឋខ្មែរដែលបានធ្វើទេសន្តរប្រវេសន៍ទៅកាន់ប្រទេសម៉ាឡេស៊ី ធ្វើជាអ្នកបម្រើតាមផ្ទះ ត្រូវបានម្ចាស់ផ្ទះវាយធ្វើបាប និងបង្កឱ្យមានរបួសស្នាមយ៉ាងធ្ងន់ធ្ងរ រហូតដល់រដ្ឋាភិបាលកម្ពុជាចេញសេចក្តីប្រកាសបញ្ឈប់ការបញ្ជូនពលករទៅធ្វើការនៅប្រទេសម៉ាឡេស៊ី និងថ្មីៗនេះ ពលករខ្មែរទាំងស្របច្បាប់ និងខុសច្បាប់ជាច្រើននាក់ ត្រូវបានអាជ្ញាធរថៃចាប់បញ្ជូនមកក្នុងប្រទេសកម្ពុជាវិញ ដោយចោទថា ពលករទាំងនោះ បានធ្វើអន្តោប្រវេសន៍ខុសច្បាប់ចូលទៅធ្វើការនៅក្នុងប្រទេសថៃ។

ទោះជាយ៉ាងនេះក្តី ក៏មានប្រជាពលរដ្ឋខ្មែរជាច្រើននៅតែបន្តធ្វើអន្តោប្រវេសន៍ខុសច្បាប់ តាមរយៈមេខ្យល់ទៅធ្វើការនៅប្រទេសទាំងនោះ និងអ្នកខ្លះទៀត ទៅស្របច្បាប់តាមរយៈក្រុមហ៊ុនជាដើម។ បញ្ហាទាំងនេះ ដោយសារតែប្រទេសកម្ពុជាមានកំណើនប្រជាជនវ័យក្មេងជាច្រើន ពីមួយឆ្នាំទៅមួយឆ្នាំ និងទីផ្សារការងារកាន់តែចង្អៀតនៅក្នុងប្រទេស។

យោងតាមជំរឿនជាតិឆ្នាំ២០០៨ បានបង្ហាញថា អត្រាកំណើនប្រជាជនគឺ ១.៥៤ ភាគរយក្នុងមួយឆ្នាំ។ នៅឆ្នាំ២០២០ ប្រជាជនកម្ពុជា ត្រូវបានប៉ាន់ស្មានថាមានចំនួន ១៨.៧ លាននាក់ ប្រៀបធៀបទៅឆ្នាំ២០០៨ មានចំនួន ១៣.៣៩ លាននាក់ និង ១១.៤៤ លាននាក់ នៅឆ្នាំ១៩៩៨។ ប្រហែល ៦០ ភាគរយនៃប្រជាជនសរុបគឺមានអាយុ ២៤ឆ្នាំ រឺទាបជាង។ កម្លាំងពលកម្មរបស់ប្រជាជនកម្ពុជា បានកើនឡើងគួរឱ្យកត់សំគាល់ពី ៥.៥០ លាននាក់ នៃកម្លាំងពលកម្មសរុបនៅឆ្នាំ១៩៩៩ និង ៧.៥០ លាននាក់ នៅឆ្នាំ២០០៤ និងបន្តកើនឡើងដល់ ៧.៨០ លាននាក់ នៅឆ្នាំ២០០៧ (វិទ្យាស្ថានជាតិ

ស្ថិតិ ២០០៩)។ ការកើនឡើងប្រចាំឆ្នាំជាមធ្យម នៃកម្លាំងពលកម្មដែលត្រូវឈានចូលទីផ្សារការងារ គឺមានចំនួនពី ២០០.០០០ នាក់ ទៅ ២០៥.០០០ នាក់ នៅក្នុងអំឡុងពេលពីឆ្នាំ១៩៩៩ ដល់ ២០០៤ និងប្រហែល ២៣០.០០០ នាក់ ទៅ ២៧០.០០០ នាក់ ក្នុងមួយឆ្នាំក្នុងអំឡុងពេលពីឆ្នាំ២០០៤ ដល់ ២០០៨ ជាមួយនឹងចំនួនដ៏ច្រើននេះ បណ្តាលឱ្យមានយុវជនជាច្រើនខ្វះការងារធ្វើ។ ការផ្គត់ផ្គង់កម្លាំងពលកម្ម ដ៏ច្រើនលើសលុបនេះ គឺបណ្តាលមកពី សន្ទុះកំណើតខ្លាំងនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ និង ១៩៩០។ ដើម្បីឆ្លើយតបនឹងតម្រូវការការងារនេះ គម្រោងវិនិយោគជាច្រើនត្រូវបានអនុវត្តន៍ដែលអាចផ្តល់ការងារប្រហែល ៦៧.០០០ នាក់ ក្នុងមួយឆ្នាំនៅក្នុងអំឡុងពេលពីឆ្នាំ១៩៩៩ ដល់ ២០០៤។ ប៉ុន្តែ វានៅតែមិនគ្រប់គ្រាន់ ដើម្បីស្រូបយកកំណើននៃការផ្គត់ផ្គង់ការងារដែលមានប្រហែលជា២៧ ភាគរយ នៃ ប្រជាជន ២៧០.០០០ នាក់ ដែលឈានចូលទីផ្សារការងារជារៀងរាល់ឆ្នាំទេ។ នៅក្នុងចំណោមអ្នកស្វែងរកការងារ ១០០ នាក់ នៅទីក្រុងភ្នំពេញ គឺមាន ៧២ នាក់ ជាអ្នកដែលមានអាយុ ១៥ ដល់ ២៤ឆ្នាំ (EIC 2006)។[1]

[1] ទំព័រទី ២, ចំណុច ១.២, ទេសន្តរប្រវេសន៍ និងការអភិវឌ្ឍនៅកម្ពុជា, វិច្ឆកា ២០០៩

# ជំពូកទី១: ទេសន្តរប្រវេសន៍ជាតិ

## ១.១. មូលហេតុនៃការធ្វើទេសន្តរប្រវេសន៍នៅកម្ពុជា

ទេសន្តរប្រវេសន៍ត្រូវបានកំណត់ថាជាដំណើរការ នៃការផ្លាស់ប្តូរលំនៅដ្ឋានពីតំបន់ទីតាំងភូមិសាស្ត្រមួយទៅទីតាំងភូមិសាស្ត្រមួយផ្សេងទៀត។ ជាង ១០ឆ្នាំកន្លងទៅនេះ ចំនួនជនទេសន្តរប្រវេសន៍នៅកម្ពុជាមានការថយចុះពី ៣.៥៩៧.៧៦៩ នាក់ នៅឆ្នាំ១៩៩៨ ទៅ ៣.៥៥២.១៧៣ នាក់នៅឆ្នាំ២០០៨។ នៅក្នុងចំណោមជនទេសន្តរប្រវេសន៍ឆ្នាំ២០០៨ មានបុរសចំនួន ១.៧៩២.៦២៥ នាក់ ស្មើនឹង ៥០.៤៦ ភាគរយ និងស្ត្រី មានចំនួន ១.៧៥៩.៧២០ នាក់ ស្មើនឹង ៤៩.៥៤ ភាគរយ។ ភាគរយនៃជនទេសន្តរប្រវេសន៍ នៅក្នុងចំណោមប្រជាជនសរុប ក៏មានការថយចុះផងដែរ គឺពី ៣១.៤៦ ភាគរយ មកនៅ ២៦.៥២ ភាគរយ នៅឆ្នាំ១៩៩៨ និង ២០០៨ រៀងគ្នា។

តារាងទី១: ការបែងចែកទេសន្តរប្រវេសន៍នៅកម្ពុជា១៩៩៨ និង ២០០៨[2]

| លំនៅដ្ឋានមុន | ទាំងពីរភេទ | | បុរស | | ស្ត្រី | |
|---|---|---|---|---|---|---|
| | ១៩៩៨ | ២០០៨ | ១៩៩៨ | ២០០៨ | ១៩៩៨ | ២០០៨ |
| ចំនួនអ្នកផ្លាស់ប្តូរទីលំនៅ | ៣.៥៩៧.៧៦៩ | ៣.៥៥២.១៧៣ | ១.៧៨៩.៦១៦ | ១.៧៩២.៥១៩ | ១.៨០៨.១៥៣ | ១.៧៥៩.៦៥៤ |
| សរុប | ១០០% | ១០០% | ១០០% | ១០០% | ១០០% | ១០០% |
| ផ្លាស់ទីនៅក្នុងខេត្ត | ៥៨.៨៤ | ៥១.៣៤ | ៥៩.៦៥ | ៥២.២៦ | ៥៨.០២ | ៥០.៤១ |
| ចេញទៅខេត្តផ្សេងទៀត | ៣៥.៣១ | ៤៥.៩៩ | ៣៤.៥៦ | ៤៥.០៤ | ៣៦.០៦ | ៤៦.៩៥ |
| ចេញក្រៅប្រទេសកម្ពុជា | ៥.៨៥ | ២.៦៧ | ៥.៧៩ | ២.៧០ | ៥.៩២ | ២.៦៥ |

ការធ្វើទេសន្តរប្រវេសន៍ បណ្តាលមកពីហេតុផលជាច្រើន។ មូលហេតុនៃការផ្លាស់ប្តូរទីលំ នៅរបស់ក្រុមគ្រួសារគឺជាកត្តាមួយសំខាន់ជាងគេនៅក្នុងចំណោមហេតុផលផ្សេងៗ ទៀត។ នៅឆ្នាំ២០០៨ មូលសម្រាប់ការផ្លាស់ប្តូរទីលំនៅរបស់ក្រុមគ្រួសារគឺមាន ៣៦.៩៧ ភាគរយ និងមូលហេតុបន្ទាប់គឺការស្វែងរកការងារធ្វើដែលមាន ២១.៥២ ភាគរយ និងការផ្លាស់ប្តូរទីលំនៅ ដោយសារការរៀបអាពាហ៍ពិពាហ៍មាន ១៤.៦២ ភាគរយ។ បើប្រៀបធៀបទៅនឹងឆ្នាំ១៩៩៨ មូលហេតុនៃការធ្វើទេសន្តរប្រវេសន៍ដោយសារការផ្លាស់ប្តូរទីលំនៅតាមក្រុមគ្រួសារមាន ៣៦.៩៧ ភាគរយ និងមូល

[2] វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ: ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ២០០៨

ហេតុនៃការស្វែងរកការងារធ្វើមាន ១១.៥៥ ភាគរយ និងការផ្លាស់ប្តូរទីលំនៅដោយសារការរៀបអាពាហ៍ពិពាហ៍មាន ១៣.១៥ ភាគរយ។ កត្តាជំរុញផ្សេងទៀដូចជាភាពគ្មានដីធ្លី និងភាពក្រីក្រនៅទីជនបទមិនអាចផ្តល់ការងារគ្រប់គ្រាន់ ដល់កម្លាំងពលកម្មនៅជនបទ និងអ្នកដែលដល់វ័យចូលទីផ្សារការងារថ្មី។ ឱកាសការងារឱណាមិច របស់ប្រជាជន របៀបរបបនៃការរស់នៅ និងភាពទាន់សម័យនៅទីប្រជុំជនក៏ដូចជាកត្តាសំខាន់ដែលទាក់ទងនឹង យុវវ័យកម្ពុជា ធ្វើការចាកចេញពីស្រុកកំណើតទៅទីប្រជុំជន។[3]

### តារាងទី២: មូលហេតុនៃការធ្វើទេសន្តរប្រវេសន៍នៅកម្ពុជា១៩៩៨ និង ២០០៨[4]

| មូលហេតុនៃការផ្លាស់ប្តូរទីលំនៅ | ទាំងពីរភេទ | | បុរស | | ស្ត្រី | |
|---|---|---|---|---|---|---|
| | ១៩៩៨ | ២០០៨ | ១៩៩៨ | ២០០៨ | ១៩៩៨ | ២០០៨ |
| ប្តូរកន្លែងរកការងារ | ៣.៥៩៧.៧៦៩ | ៣.៥៥២.១៧៣ | ១.៧៨៩.៦១៦ | ១.៧៩២.៥១៩ | ១.៨០៨.១៥៣ | ១.៧៥៩.៦៥៤ |
| ស្វែងរកការងារ | ១០០% | ១០០% | ១០០% | ១០០% | ១០០% | ១០០% |
| ការសិក្សារ | ៥៨.៨៤ | ៥១.៣៤ | ៥៩.៦៥ | ៥២.២៦ | ៥៨.០២ | ៥០.៤១ |
| រៀបអាពាហ៍ពិពាហ៍ | ៣៥.៣១ | ៤៥.៩៩ | ៣៤.៥៦ | ៤៥.០៤ | ៣៦.០៦ | ៤៦.៩៥ |
| គ្រួសារផ្លាស់ប្តូរទីលំនៅ | ៥.៨៥ | ២.៦៧ | ៥.៧៩ | ២.៧០ | ៥.៩២ | ២.៦៥ |
| មាតុភូមិនិវត្ត | ១៣.៩២ | ១.១៩ | ១២.៦៩ | ១.២៥ | ១៥.១៥ | ១.១៣ |
| គ្រោះធម្មជាតិ | ៦.០២ | ០.១៤ | ៥.៦៦ | ០.១៤ | ៦.៣៨ | ០.១៣ |
| អសន្តិសុខ | - | ១.៩៣ | - | ១.៧៧ | - | ២.០៩ |
| កូនកំព្រា | - | ៥.៧៧ | - | ៥.១៨ | - | ៦.៣៧ |
| បាត់បង់ដីធ្លី ឬទីលំនៅ | - | ០.៣៦ | - | ០.៣៨ | - | ០.៣៤ |
| មកលេង | ១.៦០ | ៣.៦៧ | ១.៤៣ | ២.៦៨ | ១.៧៦ | ៤.៦៨ |
| មូលហេតុផ្សេងៗ | ៣.៤៦ | ០.៩៩ | ៣.១០ | ១.២ | ៣.៨១ | ០.៧៧ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

[3] ទំព័រទី ៦, ៧, ៨, ចំណុច ២.១, ២.២, ទេសន្តរប្រវេសន៍ និងការអភិវឌ្ឍនៅកម្ពុជា, វិច្ឆកា ២០០៩

[4] វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ: ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ២០០៨

### តារាងទី៣: ការបែងចែកទេសន្តរប្រវេសន៍ជនបទ និងទីប្រជុំជននៅកម្ពុជា១៩៩៨ និង ២០០៨[6]

| ទេសន្តរប្រវេសន៍ក្នុងប្រទេស | ទីប្រជុំជន | | ជនបទ | | សរុប | |
|---|---|---|---|---|---|---|
| | ១៩៩៨ | ២០០៨ | ១៩៩៨ | ២០០៨ | ១៩៩៨ | ២០០៨ |
| ទាំងពីរភេទ | ៦២៦.៦០២ | ៧៤៦.៥៥៣ | ២.៧៦០.៥៣៨ | ២.៧១០.៦៧៥ | ៣.៣៨៧.១៤០ | ៣.៤៥៧.២២៨ |
| បុរស | ៣១១.១៣២ | ៣៦៩.៤២៧ | ១.៣៧៤.៨៥៤ | ១.៣៧៤.៦១៧ | ១.៦៨៥.៩៨៦ | ១.៧៤៤.០៤៤ |
| ស្ត្រី | ៣១៥.៤៧០ | ៣៧៧.១២៦ | ១.៣៨៥.៦៨៤ | ១.៣៣៦.០៥៨ | ១.៧០១.១៥៤ | ១.៧១៣.១៨៤ |

### តារាងទី៤: ភាគរយនៃការបែងចែកទេសន្តរប្រវេសន៍នៅកម្ពុជា១៩៩៨ និង ២០០៨[5]

| ទេសន្តរប្រវេសន៍ក្នុងប្រទេស | ទាំងពីរភេទ | | បុរស | | ស្ត្រី | |
|---|---|---|---|---|---|---|
| | ១៩៩៨ | ២០០៨ | ១៩៩៨ | ២០០៨ | ១៩៩៨ | ២០០៨ |
| ជនបទ-ជនបទ | ៥៨.០០ | ៥០.៨៨ | ៥៩.០៥ | ៥៣.២៦ | ៥៦.៩៨ | ៤៨.៤៥ |
| ជនបទ-ទីប្រជុំជន | ២៣.៥០ | ២៧.៥៣ | ២២.៥០ | ២៥.៥៦ | ២៤.៤៨ | ២៩.៥៤ |
| ទីប្រជុំជន-ជនបទ | ៥.១៦ | ៦.៤៨ | ៥.៣៧ | ៦.៧៩ | ៤.៩៥ | ៦.១៦ |
| ទីប្រជុំជន-ទីប្រជុំជន | ១៣.៣៤ | ១៥.១១ | ១៣.០៨ | ១៤.៣៩ | ១៣.៥៩ | ១៥.៨៥ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

[5] វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ: ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ២០០៨

[6] វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ: ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ២០០៨

## ១.២. ទីកន្លែងគោលដៅការងារនៅទីប្រជុំជន

រាជធានីភ្នំពេញ គឺជាទីកន្លែងគោលដៅការងារសំខាន់ជាងគេនៅក្នុងប្រទេសដែលទទួលជនទេសន្តរប្រវេសន៍ ប្រហែលជាមួយភាគបីដែលមកពីបណ្តាខេត្តនានា។ បន្ទាប់មក ខេត្តកណ្តាល បន្ទាយមានជ័យ សៀមរាប និងកោះកុង។ រាជធានីភ្នំពេញ និងខេត្តកណ្តាលគឺជាតំបន់ទីប្រជុំជនសំខាន់ជាងគេ និងជាកន្លែងគោលដៅ ដែលពុំមានវិស័យកសិកម្ម ចំណែកឯតំបន់ទីប្រជុំជនបីផ្សេងទៀតគឺ ខេត្តបន្ទាយមានជ័យ សៀមរាប និងកោះកុង មានទីកន្លែងសម្រាប់ប្រកបរបរកសិកម្មមធ្យម និងមានដង់ស៊ីតេប្រជាជនទាប។ ដូច្នេះហើយបានជាជនទេសន្តរប្រវេសន៍ ធ្វើបំលាស់ទីទៅកាន់ទីកន្លែងណាដែលពួកគេគិតថា មានសក្តានុពលការងារខ្លាំងសម្រាប់ពួកគេ (វិទ្យាស្ថានជាតិស្ថិតិ ២០០៥)។ កត្តាទាំងនេះគឺបណ្តាលមកពីទីប្រជុំជនសំខាន់ៗ ជាទីកន្លែងដែលមានការរីចម្រើនសេដ្ឋកិច្ច ទេសចរណ៍ និងការកើនឡើងផ្នែកឧស្សាហកម្ម នៅក្នុងអត្រាមួយឆាប់រហ័សខ្លាំង។

រូបភាពទី ១៖ ទីកន្លែងគោលដៅការងារសម្រាប់ជនទេសន្តរប្រវេសន៍ វៃយជំទង់ពីជនបទ ទៅទីប្រជុំជន[7]




[7] វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ឆ្នាំ២០០៧

តម្រូវការខ្ពស់នៃពលករដែលគ្មានជំនាញនៅក្នុងឧស្សាហកម្មកាត់ដេរ សំណង់ និងទេសចរណ៍ គឺជាកត្តាអូសទាញ មួយយ៉ាងសំខាន់។ ពលករភាគច្រើនបានសម្រេចចិត្តធ្វើការផ្លាស់ប្តូរ ទីលំនៅ ដោយសារភាពអត់ការងារធ្វើ និងប្រាក់ចំណូលនៅទីជនបទមានកម្រិតទាប។ កម្មករដែលធ្វើការ នៅទីជនបទទទួលបានប្រាក់ចំណូលពី ៣.៥០០ រៀល ទៅ ៤.០០០ រៀល ក្នុងមួយថ្ងៃនៅក្នុងវិស័យ កសិកម្ម និង ៣.៨០០ រៀល ទៅ ៤.២០០ រៀល ក្នុងមួយថ្ងៃសម្រាប់វិស័យដែលមិនមែនកសិកម្ម (ធនាគារពិភពលោក ២០០៥)។ ចំណែកឯប្រាក់ចំណូលនៅទីប្រជុំជនវិញ គឺមានកម្រិតខ្ពស់ជាង ប្រាក់ឈ្នួលអប្បបរមាដែលផ្តល់ឱ្យនៅតំបន់ជនបទ។ សម្រាប់ការងារដែលមានស្ថេរភាពអាចផ្តល់ ប្រាក់ចំណូលដល់ជនទេសន្តរប្រវេសន៍ពី ៦០ ទៅ ៧០ ដុល្លារអាមេរិកក្នុងមួយខែ ដែលបានអូស ទាញយុវវ័យជាច្រើន ជាពិសេសស្ត្រីនៅលីវឱ្យធ្វើបំលាស់ទីពីស្រុកកំណើតរបស់ពួកគេទៅកាន់ទី ប្រជុំជននានាក្នុងប្រទេស។[8]

## ១.៣. សារៈសំខាន់នៃយេនឌ័រ សម្រាប់ទេសន្តរប្រវេសន៍ការងារ

តម្រូវការពលការនីនៅក្នុងវិស័យឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ បណ្តាលឱ្យមានការកើន ឡើងការធ្វើបំលាស់ទីស្ត្រីវ័យក្មេងជាច្រើន ពីទីជនបទទៅកាន់រាជធានីភ្នំពេញ និងតំបន់ទីប្រជុំជន ផ្សេងទៀត។ លើសពីនេះទៅទៀត នៅក្នុងវិស័យដែលមិនផ្លូវការផ្សេងទៀត បានស្រូបយកជន ទេសន្តរប្រវេសន៍ជាស្ត្រីពីតំបន់ជនបទឱ្យបម្រើការងារនៅក្នុងវិស័យមួយចំនួនផ្សេងទៀត ដូចជា អ្នកលក់ដូរតាមចិញ្ចើមថ្នល់ ការងារសំណង់ ការងារដោយដៃ ការងារផ្ទះ ការងារប្រមូល សំរាម។ល។ ការងារទាំងនេះមិនស្ថិតនៅក្រោមច្បាប់ការងារ ដែលជាហេតុបណ្តាលឱ្យមាន លក្ខខណ្ឌការងារមិនល្អ និងគ្មានសន្តិសុខសង្គមសម្រាប់អ្នកបំលាស់ទី (ធនាគារពិភពលោក ឆ្នាំ២០០៦)។

ប៉ុន្តែដោយសារការអប់រំទាប និងអនក្ខរភាព ពលការនីខ្មែរប្រឈមមុខនឹងបញ្ហាជាច្រើននៅក្នុង ការទទួលបានការងារល្អ និងបានប្រាក់កម្រៃខ្ពស់ទាំងនៅក្នុង និងនៅក្រៅប្រទេស។ នៅក្នុង ប្រទេសកម្ពុជា ឱកាសការងារមានតិចតួចសម្រាប់ស្ត្រីដែលមានជំនាញតិច លើកលែងតែនៅក្នុង វិស័យឧស្សាហកម្មកាត់ដេរប៉ុណ្ណោះ។ នៅឆ្នាំ២០០៥ ក្នុងចំណោមផលិតផលនាំចេញសរុបរបស់

[8] ទំព័រទី ៩, ចំណុច ២.៣, ទេសន្តរប្រវេសន៍ និងការអភិវឌ្ឍនៅកម្ពុជា, វិច្ឆកា ២០០៩

ប្រទេសកម្ពុជា ផលិតផលឧស្សាហកម្មកាត់ដេរ មានចំនួនរហូតដល់ ៨០.៤ ភាគរយ។ វិស័យនេះបានស្រូបយកកម្លាំងពលកម្មផ្ទាល់ និងមិនផ្ទាល់ មានចំនួនច្រើនជាង ២៥០.០០០ នាក់ នៅឆ្នាំ ២០០៤ និង ៣៥៨.០០០ នាក់ នៅឆ្នាំ២០០៧។ ៨៥ ភាគរយ នៃកម្មករកាត់ដេរគឺជាស្ត្រីដែលភាគច្រើនគឺមកពីទីជនបទ។

សេចក្តីសង្ឃឹមលើការងារជាក់ស្តែងជាមួយនឹងប្រាក់កម្រៃ ដែលពួកគេអាចរកបានជាមធ្យមនៅចន្លោះ ៦០ ទៅ ៧០ ដុល្លារអាមេរិក ក្នុងមួយខែ។ កត្តានេះហើយធ្វើឱ្យស្ត្រីដែលមិនទាន់រៀបការភាគច្រើនបានធ្វើការបំលាស់ទីពីភូមិកំណើតរបស់ពួកគេទៅកាន់ទីប្រជុំជន ដែលមានការរីកចម្រើនខាងសេដ្ឋកិច្ច ទេសចរណ៍ ឬឧស្សាហកម្មដើម្បីងាយស្រួលស្វែងរកការងារ។ ក្រៅពីនេះទៀត ជនទេសន្តរប្រវេសន៍ជាស្ត្រីមួយចំនួនទៀត បានរកការងារធ្វើនៅក្នុងវិស័យការងារមិនផ្លូវការ ដូចជាអ្នកបម្រើតាមផ្ទះ អ្នកកាត់សក់ អ្នកលក់សាំង និងបារី អ្នកដុសខាត់សម្អាតក្រចក អ្នកជំនួយការនៅក្នុងហាងលក់ទំនិញ អ្នកលក់ផ្លែឈើ អាហារដ្ឋាន និងជាកម្មករ។ល។

នៅក្នុងករណីមួយចំនួនទៀត ដើម្បីទទួលបានប្រាក់ចំណូលខ្ពស់សម្រាប់ក្រុមគ្រួសាររបស់ពួកគេ ជនទេសន្តរប្រវេសន៍មួយចំនួនត្រូវទទួលរងនូវលក្ខខណ្ឌការងារមិនល្អនៅតំបន់ទីប្រជុំជន និងលក្ខខណ្ឌរស់នៅមិនសមរម្យនៅក្នុងអំឡុងពេលនៃការធ្វើទេសន្តរប្រវេសន៍។ ជនទេសន្តរប្រវេសន៍ជាស្ត្រីភាគច្រើនដែលធ្វើការនៅក្នុងរោងចក្រប្រឈមមុខជាមួយនឹងមេរោគ និងជម្ងឺផ្សេងៗ ដោយសារតែពួកគេ មានការយល់ដឹងពីសុខភាពផ្លូវភេទទាបជាងស្ត្រី ដែលធ្វើការនៅក្នុងវិស័យកម្សាន្ត និងស្ត្រីដែលបានរៀបការរួច។ តាមការសិក្សាស៊ីជម្រៅជាមួយនឹងស្ត្រី ២០នាក់ ដែលមិនទាន់រៀបការ ធ្វើការនៅក្នុងរោងចក្រកាត់ដេរបានរាយការណ៍ថា ពួកគេមានទំនាក់ទំនងស្នេហាដោយផ្ទាល់ជាមួយដៃគូរច្រើន ដែលបណ្តាលឱ្យពួកគេប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ខ្ពស់។ ដោយសារស្ថានភាពសង្គមសេដ្ឋកិច្ចទាប ដូចជាការអប់រំទាប ប្រាក់កម្រៃទទួលបានពីការងារទាប និងអត្រាមិនឯករាជ្យខ្ពស់នៅគ្រួសារជនបទ និងកាតព្វកិច្ចជាកូនស្រី ត្រូវជួយដល់ក្រុមគ្រួសារ ដែលជាកត្តាមួយធ្វើឱ្យពួកគេងាយចូលខ្លួនទៅបម្រើការងារនៅក្នុងវិស័យកម្សាន្តដែរ។[9]

[9] ទំព័រទី ១០, ១១, ចំណុច ២.៤, ទេសន្តរប្រវេសន៍ និងការអភិវឌ្ឍនៅកម្ពុជា, វិច្ឆកា ២០០៩

## ១.៤. ផលប៉ះពាល់លើសុខភាពពីការធ្វើទេសន្តរប្រវេសន៍ ពីទីជនបទ ទៅទីប្រជុំជន

ផលប៉ះពាល់ផ្នែកសុខភាពពីការធ្វើទេសន្តរប្រវេសន៍ពីទីជនបទ ទៅទីប្រជុំជន អាចជាបញ្ហាយ៉ាងសំខាន់ដែលប្រឈមមុខដោយរាជរដ្ឋាភិបាលកម្ពុជា (RGC)។ កត្តាសំខាន់មួយនៅក្នុងកត្តាផ្សេងទៀត សម្រាប់ភាពជោគជ័យផ្នែកសេដ្ឋកិច្ច និងសង្គម គឺបញ្ហាសុខភាពល្អ ជាកត្តាសំខាន់សម្រាប់ធានាថា ប្រជាជនផ្តល់ផលិតភាពការងារខ្ពស់ និងជៀសវាង បានការចំណាយខ្ពស់លើការថែទាំសុខភាព។ សុខភាព អាចជាមូលហេតុមួយ និងផល់ប៉ះពាល់ចំពោះភាពក្រីក្រដល់បុគ្គល និងប៉ះពាល់ដល់សហគមន៍ដោយគ្មានការងារធ្វើ និងជាប់ជំពាក់បំណុលគេ ដោយសារការចំណាយលើថ្នាំពេទ្យ។

ជនទេសន្តរប្រវេសន៍ ដែលបានចាកចេញពីទីជនបទ ទៅកាន់ទីប្រជុំជនជួបប្រទះហានិភ័យ និងការប្រឈមមុខជាច្រើននៅពេលមកតាំងទីលំនៅនៅទីក្រុង ជាទីកន្លែងដែលពួកគេត្រូវស្វែងរកមុនគេគឺផ្ទះស្នាក់នៅ មានតម្លៃសមរម្យ។ ជនទេសន្តរប្រវេសន៍ជាច្រើន អាចទទួលបានការងារតាមរយៈទំនាក់ទំនងសង្គម និងការសូកប៉ាន់។ ជនទេសន្តរប្រវេសន៍ជាច្រើនផ្សេងទៀត ត្រូវបានបង្ខំឱ្យធ្វើការផ្លាស់ប្តូរលំនៅដ្ឋានក្នុងសហគមន៍ ដែលមិនរៀបរយ និងកង្វះទីកន្លែងរស់នៅមានសុវត្ថិភាព គឺជាផលប៉ះពាល់អវិជ្ជមានដល់សុខភាពរបស់ជនទេសន្តរប្រវេសន៍។ ជាពិសេស ធ្វើឱ្យមានមនុស្សកុះករច្រើនពេកនៅទីប្រជុំជន និងអាចជួបប្រទះនូវកង្វះខាតមួយចំនួន ដូចជា ការប្រើប្រាស់ទឹកស្អាត ភ្លើង និងប្រព័ន្ធបញ្ចេញកាកសំណល់។ ជាលទ្ធផលពួកគេជួបនូវបញ្ហាជាញឹកញាប់ ដូចជាការបោះចោលកាកសំណាល់ ជម្ងឺរាគរូស ជម្ងឺគ្រុនពោះវៀន និងមេរោគចម្លងជម្ងឺផ្សេងៗ។[10]

[10] ទំព័រទី ១១, ចំណុច ២.៥, ទេសន្តរប្រវេសន៍ និងការអភិវឌ្ឍនៅកម្ពុជា, វិច្ឆកា ២០០៩

# ជំពូកទី២: ទេសន្តរប្រវេសន៍អន្តរជាតិ

វិស័យពាណិជ្ជកម្មអន្តរជាតិ ការវិនិយោគបរទេសផ្ទាល់ (FDI) និងការធ្វើទេសន្តរប្រវេសន៍អន្តរជាតិ បានក្លាយជាបណ្តាញសំខាន់មួយ សម្រាប់ការផ្ទេរបច្ចេកវិទ្យា លំហូររូបិយប័ណ្ណ និងចំណេះដឹង។ ប៉ុន្តែ ទិសដៅ និងទំហំនៃលំហូរបច្ចេកវិទ្យាដែលបណ្តាលមកពីការធ្វើទេសន្តរប្រវេសន៍អន្តរជាតិ គឺមិនមានភាពច្បាស់លាស់ ដូចការវិនិយោគបរទេសផ្ទាល់ និងពាណិជ្ជកម្មអន្តរជាតិទេ។ រាជរដ្ឋាភិបាលកម្ពុជាក៏ដូចជា រដ្ឋាភិបាលនៃប្រទេសនានានៅក្នុងតំបន់ បានខិតខំជំរុញការនាំចេញពលករខ្មែរទៅធ្វើការងារនៅក្រៅប្រទេស។ ការធ្វើទេសន្តរប្រវេសន៍ការងារអន្តរជាតិរបស់ប្រជាជនកម្ពុជាត្រូវបានកំណត់ និងបានចែងនៅក្នុងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (NPRS) " ការនាំចេញពលករ គឺជាជម្រើសមួយយ៉ាងសំខាន់សម្រាប់ការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសអាស៊ីជិតខាងកម្ពុជាដូចជា ហ្វីលីពីន សិរីលង្កា ថៃ និងវៀតណាម។ គោលនយោបាយរបស់រដ្ឋាភិបាល គឺជំរុញលើកទឹកចិត្តការនាំចេញកម្លាំងពលកម្មដោយស្របច្បាប់ក្នុងគោលបំណងបង្កើនសុខុមាលភាព បង្កើនជំនាញវិជ្ជាជីវៈ កាត់បន្ថយភាពអត់ការងារធ្វើនិងបង្កើនប្រាក់ចំណូលរបស់រដ្ឋ"។

ចាប់តាំងពីឆ្នាំ១៩៩៥ ប្រទេសកម្ពុជា ត្រូវបានចាត់ទុកជាប្រទេសមួយដែលបញ្ជូនពលករចេញទៅធ្វើការក្រៅប្រទេសនៅក្នុងតំបន់។ កម្ពុជាគឺជាប្រទេសនាំចេញពលករមួយយ៉ាងសំខាន់ទៅប្រទេសអាស៊ី ដូចជាប្រទេសថៃ ម៉ាឡេស៊ី កូរ៉េខាងត្បូង និងប្រទេសនៅតំបន់ឈូងសមុទ្រមានដូចជា អារ៉ាប់ប៊ីសាអូឌីត និងកាតា។ នៅពេលថ្មីៗ កន្លងទៅនេះ រាជរដ្ឋាភិបាលកម្ពុជា ក៏បានចុះអនុស្សារណៈយោគយល់គ្នាជាមួយប្រទេសគុយវេត ដើម្បីបញ្ជូនពលករកម្ពុជាឱ្យទៅធ្វើការនៅទីនោះ។[11]

[11] ទំព័រទី ១២, ចំណុច ៣, ទេសន្តរប្រវេសន៍ និងការអភិវឌ្ឍនៅកម្ពុជា, វិច្ឆកា ២០០៩

## ២.១. មូលហេតុនៃការធ្វើទេសន្តរប្រវេសន៍នៅបរទេស

នៅប្រទេសកំពុងអភិវឌ្ឍន៍ គេមិនទាន់បានបង្កើតការងារមេសមរម្យ គ្រប់គ្រាន់ដើម្បីស្រូបយកកំណើនចំនួនមនុស្ស ដែលចូលដល់កម្លាំងពលកម្មជារៀងរាល់ឆ្នាំ នៅឡើយទេ។ ការគំរាមកំហែងចំពោះសន្តិសុខរបស់ជនទេសន្តរប្រវេសន៍ មានជាអាទិ៍ គ្រោះមហន្តរាយធម្មជាតិ ការប៉ះទង្គិចនៃសេដ្ឋកិច្ចពីខាងក្រៅ ការធ្លាក់ចុះយ៉ាងលឿន នូវតម្លៃផលិតផលកសិកម្ម ឯកជនភាវូបនីយកម្ម និងការថយចុះចំនួនសហគ្រាសរដ្ឋ ការចុះតម្លៃនៃក្រដាសប្រាក់ និងបរាជ័យនៃធនាគារ ជំរុញឱ្យគ្រួសារទាំងឡាយត្រូវសម្រេចចិត្ត ដោយគ្មានជម្រើសបញ្ជូនសមាជិកគ្រួសារខ្លួនទៅធ្វើការនៅបរទេស។[12]

**កត្តារុញច្រាន និងអូសទាញ:** ចំពោះករណីទេសន្តរប្រវេសន៍នៃកម្មករ យើងត្រូវសម្លឹងមើលលើកត្តា សេដ្ឋកិច្ចដែល វាអាចបកស្រាយបាននូវចលនាផ្លាស់ទីនេះ។ កត្តាទាំងនេះ ត្រូវបានអ្នកនិពន្ធទាំងពួងហៅយ៉ាងសាមញ្ញថា កត្តា " រុញច្រាន" និង កត្តា "អូសទាញ"។ កត្តាអូសទាញ គឺជាកត្តាដែលគេអាចដឹងតម្រុយអំពីតម្រូវការការងារច្រើន លើសលប់នៅបរទេសក្នុងខណៈកត្តារុញច្រាន គឺជាទូទៅអាចរកតម្រុយអំពីការផ្គត់ផ្គង់ការងារច្រើនលើសលប់នៅក្នុងប្រទេស និងមានប្រាក់ឈ្នួលទាប និងអត្រានិកម្មភាពខ្ពស់។[13]

**កត្តាបណ្ដាញ:** ក្នុងពេលដែលជនទេសន្តរប្រវេសន៍ទាំងឡាយបានកសាងខ្លួនឯងនៅប្រទេសក្រៅណាមួយជាធម្មតា គេតែងមានបំណងអូសទាញសាច់ញាតិ និងមិត្តភ័ក្តិឱ្យមកធ្វើការជាមួយខ្លួន។ កត្តាបែបនេះ ហៅថាកត្តា "បណ្ដាញ"។ ឧទាហរណ៍: នៅតំបន់ព្រំដែនភាគខាងកើតនៃប្រទេសភូមា ជាតំបន់ដែលមានជម្លោះយ៉ាងយូរជាមួយនឹងរដ្ឋាភិបាលកណ្ដាល ហើយភាពក្រីក្របានរុញច្រានឱ្យមនុស្សជាច្រើនឆ្លងដែនទៅប្រទេសថៃ។ ចាប់ពីខេត្តនានានៅតាមទល់ដែន ពួកគេបានផ្លាស់ទីទៅទីក្រុងបាងកក និងទៅកន្លែងផ្សេងៗក្នុងប្រទេសថៃ ជាមួយគ្នានោះដែរ ពួកគេបានជួយដល់អ្នកដែលកំពុងរស់នៅប្រទេសភូមាឱ្យឆ្លងដែន និងស្វែងរកការងារផ្នែកសំណង់ សេវាកម្ម

---

[12] ទំព័រទី ១៣, កថាខណ្ឌទី ១, គោលនយោបាយ និងការគ្រប់គ្រងពលកម្មទេសន្តរប្រវេសន៍, ម៉ូឌុលបណ្ដុះបណ្ដាល

[13] ទំព័រទី ១៣, កថាខណ្ឌទី ២, គោលនយោបាយ និងការគ្រប់គ្រងពលកម្មទេសន្តរប្រវេសន៍, ម៉ូឌុលបណ្ដុះបណ្ដាល

និងនេសាទ។ ទន្ទឹមនឹងកត្តារុញច្រានវិសាមញ្ញមានសារសំខាន់យ៉ាងជាក់ស្តែង នៅពេលចាប់ផ្តើមនៃទេសន្តរប្រវេសន៍ ប៉ុន្តែកត្តាបណ្តាញដែលរួមបញ្ចូលនូវមនុស្ស មានបំណងផ្សារភ្ជាប់ការរស់នៅជាមួយគ្រួសាររបស់ខ្លួន ក៏ជាកត្តាដែលមានលក្ខណៈកំណត់ច្បាស់លាស់ជាង នៅក្នុងលំហូរនៃទេសន្តរប្រវេសន៍។[14]

**ការផ្គត់ផ្គង់បង្កើនតម្រូវការខ្លួនឯង:** ទេសន្តរប្រវេសន៍គឺជាបាតុភូតមួយបង្ហាញថា "ការផ្គត់ផ្គង់បង្កើនតម្រូវការខ្លួនឯង"។ នៅពេលចាប់ផ្តើមការផ្គត់ផ្គង់បង្កើតលក្ខខណ្ឌដើម្បីនិរន្តរភាព និងវិត្តាកម្មរបស់ខ្លួន។ រឿងនេះគឺជាការពិតដូចគ្នារវាងតម្រូវការសេវាកម្មនៃកម្មករធ្វើការតាមផ្ទះ និងតម្រូវការកម្មករនៅក្នុងខ្សែសង្វាក់ផលិតកម្មរោងចក្រ។ ភាពអាចរកបានកម្មករបរទេសដែលយកប្រាក់ឈ្នួលទាប អាចធ្វើឱ្យឧស្សាហកម្មអតិពលកម្មបន្តរស់រានដោយមិនចាំបាច់ធ្វើការសើរើរចនាសម្ព័ន្ធ។ ជាពិសេស ចំពោះឧស្សាហកម្មខ្នាតតូច មានបច្ចេកវិទ្យាទាប ដែលរដ្ឋាភិបាលនានាមិនសូវយកចិត្តទុកដាក់ ដោយហេតុថាជាធម្មតារដ្ឋាភិបាលទាំងឡាយ ត្រូវការលើកកម្ពស់ផ្នែកសេដ្ឋកិច្ចខ្នាតធំៗ និង អាចខំប្រឹងទប់ទល់ចំពោះអ្នកធ្វើគោលនយោបាយ។ នៅក្នុងប្រទេសខ្លះ ផ្នែកសេដ្ឋកិច្ចខាតតូចមានសារសំខាន់ជាយុទ្ធសាស្ត្រ ដោយសារ វាជាទ្រនាប់ការពារចំពោះដំណើរប្រែប្រួលឡើងចុះនៅក្នុងទីផ្សារនាំចេញ។ នៅក្នុងនាមជាអ្នកចុះកិច្ចសន្យាបន្តពីសហគ្រាសធំៗ ដែលមានភាពបត់បែនតិចតួច ចំពោះការបញ្ឈប់កម្មករ នៅពេលមានការធ្លាក់ចុះនូវតម្រូវការសហគ្រាសតូចៗ ក្លាយជា "shock absorbers"។ កន្លងមកសហគ្រាសតូចៗ ក្លាយជាអ្នកពឹងអាស្រ័យលើកម្មរបរទេស ដូចជានៅតៃវ៉ាន់ (ខេត្តរបស់ចិន) នៅសាធារណរដ្ឋកូរ៉េ ប្រសិនបើគ្មានជួយអន្តរាគមន៍ ពីរដ្ឋាភិបាលក្នុងការកែទម្រង់រចនាសម្ព័ន្ធឧស្សាហកម្ម ឱ្យក្លាយជាមានលក្ខណៈស្វ័យប្រវត្តិជាងមុន ឬផ្លាស់ប្តូរទៅរកខ្សែសង្វាក់ផលិតថ្មីនោះទេ។[15]

[14] ទំព័រទី ១៣, កថាខណ្ឌទី ៤, គោលនយោបាយ និងការគ្រប់គ្រងពលកម្មទេសន្តរប្រវេសន៍, ម៉ូឌុលបណ្តុះបណ្តាល

[15] ទំព័រទី ១៤, កថាខណ្ឌទី ៥, គោលនយោបាយ និងការគ្រប់គ្រងពលកម្មទេសន្តរប្រវេសន៍, ម៉ូឌុលបណ្តុះបណ្តាល

## ២.២. ការធ្វើទេសន្តរប្រវេសន៍ទៅប្រទេសម៉ាឡេស៊ី

ចាប់តាំងពីឆ្នាំ១៩៩៨ រហូតដល់ ២០០៨ ចំនួនពលករទេសន្តរប្រវេសន៍ដែលបានបញ្ជូនទៅធ្វើការនៅប្រទេសម៉ាឡេស៊ី មានការកើនឡើងរហូតដល់ ១៣.៣២៤ នាក់ ក្នុងនោះមានពលករជាស្ត្រីមានចំនួនច្រើនជាងបុរសប្រាំដង។ ចំនួនពលករទេសន្តរប្រវេសន៍ មានការកើនឡើងពី ១២០ នាក់ នៅឆ្នាំ១៩៩៨ រហូតដល់ ១.៧៧៦ នាក់នៅឆ្នាំ២០០៥។ នៅឆ្នាំ២០០៦ ចំនួនពលករទេសន្តរប្រវេសន៍មានការថយចុះបន្តិច បន្តមកនៅត្រឹម ១.៦៩០ នាក់។ ប៉ុន្តែទោះបីជាយ៉ាងណា ចំនួនពលករទេសន្តរប្រវេសន៍ដែលបានបញ្ជូនមកកាន់ប្រទេសនេះ មានការកើនឡើងវិញទ្វេដងនៅឆ្នាំ២០០៧ រហូតដល់ ៣.២១៩ នាក់។ មួយផ្នែកធំនៃស្ត្រីធ្វើជាអ្នកបម្រើការតាមផ្ទះ ដូចជាអ្នករៀបចំថែទាំផ្ទះ អ្នកសម្អាតផ្ទះ អ្នកចំអិនអាហារ និងអ្នកថែទាំក្មេង។ ក្រៅពីនេះក៏មានពលករស្ត្រីធ្វើការងារនៅក្នុងរោងចក្រផងដែរ។ នៅឆ្នាំ២០០០ មានពលករជាស្ត្រីចំនួន ១១៣ នាក់ ធ្វើការនៅក្នុងរោងចក្រ។ ចំនួននេះបានកើនឡើងរហូតដល់ ៣៣៦ នាក់ នៅឆ្នាំ២០០២ ប៉ុន្តែ បានថយចុះមកនៅ ៣០១ នាក់ នៅឆ្នាំ២០០៤ និង ៣១៨ នាក់ នៅឆ្នាំ២០០៦ បន្ទាប់មកកើនឡើងរហូតដល់ ៩៣១ នាក់ នៅឆ្នាំ២០០៧។

លើសពីនេះទៅទៀត អង្គការក្រៅរដ្ឋាភិបាលមួយចំនួនបានរកឃើញផងដែរថា មានពលករជាស្ត្រីមួយចំនួនទៀត ដែលធ្វើការក្នុងឧស្សាហកម្មកម្សាន្ត។ នៅក្នុងឆ្នាំ២០០៨ ចំនួនពលករទេសន្តរប្រវេសន៍ដែលបានបញ្ជូនទៅកាន់ប្រទេសនេះ មានការថយចុះបន្តិច បើប្រៀបធៀបទៅឆ្នាំ២០០៧ ដោយសារមានការកាត់បន្ថយការទទួលពលករ ដោយនិយោជកនៅក្នុងប្រទេសនោះទទួលរងផលប៉ះពាល់នូវវិបត្តិហិរញ្ញវត្ថុពិភពលោក។

### តារាងទី៥: ចំនួនពលករទេសន្តរប្រវេសន៍កម្ពុជាធ្វើការនៅប្រទេសម៉ាឡេស៊ី[16]

| ឆ្នាំ | សរុប | បុរស | ស្ត្រី |
|---|---|---|---|
| ១៩៩៨ | ១២០ | - | ១២០ |
| ១៩៩៩ | ៨៦ | - | ៨៦ |
| ២០០០ | ៥០២ | ៣០៧ | ១៩៥ |
| ២០០១ | ៨៤៦ | ៣៤២ | ៥០៤ |
| ២០០២ | ១.០៤៩ | ២៤៦ | ៨០៣ |
| ២០០៣ | ៥៧៣ | ៧៣ | ៥០០ |
| ២០០៤ | ៨០៩ | ១០៥ | ៧០៤ |
| ២០០៥ | ១.៧៧៦ | ៤៦៧ | ១.៣០៩ |
| ២០០៦ | ១.៦៩០ | ២៣១ | ១.៤៥៩ |
| ២០០៧ | ៣.២១៩ | ១៧៤ | ៣.០៤៥ |
| ២០០៨ | ២.៦៥៤ | ៥៣ | ២.៦០១ |
| **សរុប** | **១៣.៣២៤** | **១.៩៩៨** | **១១.៣២៦** |

ពលករទេសន្តរប្រវេសន៍ធ្វើការនៅប្រទេសម៉ាឡេស៊ី ទទួលបានប្រាក់បៀវត្សជាមធ្យមចន្លោះពី១២០ ទៅ ៣៥០ ដុល្លារអាមេរិក ក្នុងមួយខែ។ កិច្ចសន្យាការងាររបស់ពលករ ជាទូទៅគឺមានរយៈពេល ២ឆ្នាំ និងអាចពន្យាបន្ថែមបានយ៉ាងច្រើន ១ ឬ ២ឆ្នាំ ទៀត។ យោងតាមអង្គការខារ៉ាមកម្ពុជា (CARAM Cambodia) ដែលបានផ្តល់ការបណ្តុះបណ្តាលដល់ពលករទៅធ្វើការនៅម៉ាឡេស៊ី មុនពេលចេញដំណើរ បានបង្ហាញអំពីការប្រឈមជាច្រើនផ្សេងទៀត ដែលពលករជាច្រើនជួបប្រទះ មានដូចជា បញ្ហាទំនាក់ទំនងជាមួយនឹងនិយោជករបស់ពួកគេ ការធ្វើការងារយូរហើយមានពេលសម្រាកតិច ការរើសអើងមិនមានថ្ងៃឈប់សម្រាកចុងសប្តាហ៍ ឬឈប់សម្រាកប្រចាំឆ្នាំ និងមានអារម្មណ៍ហាក់ដូចជានៅឯកោ និងនឹកផ្ទះ។

[16] ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០០៨

លើសពីនេះទៅទៀត បញ្ហា និងការប្រឈមមុខសំខាន់ៗ ផ្សេងទៀត ដែលពលករទេសន្តរប្រវេសន៍កម្ពុជា កំពុងជួបការលំបាកនៅប្រទេសម៉ាឡេស៊ី មានដូចជា ការដកហូតឯកសារធ្វើដំណើរទុក ការកាត់ទុកប្រាក់បៀវត្ស ឬកាត់បន្ថយប្រាក់បៀវត្ស ការបំពានលើលក្ខខណ្ឌការងារ ខ្វះសេរីភាពក្នុងការទំនាក់ទំនង និងការផ្លាស់ប្តូរទីកន្លែងការងារ មិនអាចបើកគណនីធនាគារ ឬរក្សាប្រាក់ទុកក្នុងហោប៉ៅសម្រាប់ពេលមានការបន្ទាន់ មានការកំហិត ឬមិនអាចទទួលបានសេវាថែទាំសុខភាព និងការរំលោភបំពានផ្លូវភេទ។[17]

## ២.៣. ការធ្វើទេសន្តរប្រវេសន៍ទៅប្រទេសថៃ

ការធ្វើទេសន្តរប្រវេសន៍ទៅប្រទេសថៃ ត្រូវបានបែងចែកជាពីរប្រភេទសំខាន់ៗ គឺ ទេសន្តរប្រវេសន៍រយៈពេលខ្លី នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ដែលមានពលករទេសន្តរប្រវេសន៍ភាគច្រើនជាស្ត្រី និងរយៈពេលវែង ដែលមានពលករចេញពីទីរួមខេត្តនានានៃប្រទេសកម្ពុជាទៅកាន់ចំណុចគោលដៅនានា នៅក្នុងប្រទេសថៃ ដែលមានពលករទេសន្តរប្រវេសន៍ភាគច្រើនគឺជាបុរស។

តារាងទី៦: ចំនួនពលករទេសន្តរប្រវេសន៍កម្ពុជាធ្វើការនៅប្រទេសថៃ[18]

| ឆ្នាំ | សរុប | បុរស | ស្ត្រី |
|---|---|---|---|
| ២០០៦ | ២២៦ | ២១៩ | ៤៤៥ |
| ២០០៧ | ៣.៩៣៥ | ១.៧៣៥ | ៥.៦៧០ |
| ២០០៨ | ១.៤២៥ | ៦១៩ | ២.១១៦ |
| សរុប | ៥.៥៨៦ | ២.៦៤៥ | ៨.២៣១ |

ពលករទេសន្តរប្រវេសន៍ជាបុរសភាគច្រើនធ្វើដំណើរទៅប្រទេសថៃ ដើម្បីបម្រើការងារនៅក្នុងផ្នែកនេសាទលើទូក និងនៅក្នុងរោងចក្រកែច្នៃផលិតផលត្រី។ ពួកគេអាចរកប្រាក់ចំណូលជាមធ្យមពី ១៥០ បាត ទៅ ១៨០ បាត ក្នុងមួយថ្ងៃ នៅក្នុងរោងចក្រកែច្នៃផលិតផលត្រី និងសម្រាប់ការ

[17] ទំព័រទី ១២, ១៣, ចំណុច ៣.១, ទេសន្តរប្រវេសន៍ និងការអភិវឌ្ឍនៅកម្ពុជា, វិច្ឆកា ២០០៩

[18] ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០០៨

នេសាទលើ ទូកពួកគេ ទទួលបានប្រាក់ខែពី ៤,០០០ បាត ទៅ ៨,០០០ បាត ក្នុងមួយខែ។ ជាទូទៅ ពួកគេ ធ្វើការមិនទៀងទាត់ទេ និងធ្វើទៅតាមរដូវ ហើយភាគច្រើនធ្វើការតែ ២សប្តាហ៍ប៉ុណ្ណោះក្នុង មួយខែ។ មានអ្នកបំលាស់ទីជាស្ត្រីផងដែរ ដែលកំពុងបម្រើការងារនៅក្នុងប្រទេសថៃ ជាទូទៅពួក គេបម្រើការងារតាមផ្ទះ អ្នកធ្វើម្ហូបអាហារ អ្នកថែរក្សាក្មេង និងការងារផ្ទះផ្សេងៗទៀត។

ភាគច្រើនពលករទេសន្តរប្រវេសន៍កម្ពុជា ជាស្ត្រីដែលធ្វើការងារតាមផ្ទះ ច្រើនតែជួបប្រទះ នឹងការកេងប្រវ័ញ្ចលើកម្លាំងពលកម្មជាញឹមញាប់ និងការរំលោភបំពានជាងពលករ ដែលជាជន ជាតិដទៃទៀត។ បញ្ហាទាំងនេះ គឺដោយសារតែការងារតាមផ្ទះជាប្រភេទការងារដែលមានលក្ខណៈ ឯកជន ហើយអ្នកបម្រើការងារតាមផ្ទះទាំងនោះ រស់នៅបែកមិត្តភ័ក្តិ ឬក្រុមគ្រួសារ។ ពលករ ទេសន្តរប្រវេសន៍ភាគច្រើន មិនអាចទាក់ទងនឹងនិយោជករបស់ពួកគេដោយសារបញ្ហាភាសាដែល បណ្តាលឱ្យការចរចាររបស់ពួកគេមានកម្រិតទាប និងមានការបំពានពាក្យសំដី និងលើរាងកាយ។ ចំណែក សិទ្ធិក្នុងការផ្លាស់ប្តូរទីកន្លែងក៏ត្រូវបានបំពានដោយនិយោជកដែរ ព្រោះនិយោជកបានដក ហូតឯកសារដើមរបស់កម្មករទុក។ ក្រៅពីនេះមានករណីជាច្រើនទៀត ដូចជា ពលករបម្រើការងារ តាមផ្ទះ មួយចំនួនរត់គេចខ្លួន ហើយក៏បានក្លាយជាអ្នកបំលាស់ទីខុសច្បាប់ ដែលត្រូវបានគេឃាត់ ខ្លួន។

លើសពីនេះទៅទៀត មានពលករ ដែលត្រូវបានគេរំលោភបំពានជាច្រើន ផ្សេងទៀតពី និយោជករបស់ពួកគេ ដោយសារភាពភ័យខ្លាច ការធ្វើបាប ឬការបាត់បង់សំណុំឯកសារច្បាប់ និង ពួកគេមានការព្រួយបារម្ភពីការបាត់បង់ការងារ និងចំណូលដែលជាការជួយយ៉ាងសំខាន់ដល់ក្រុម គ្រួសាររបស់ពួកគេនៅឯស្រុកកំណើត។

នៅក្នុងករណីខ្លះទៀតមានការកាត់ទុក ឬមិនបង់ប្រាក់ឈ្នួលដល់ពលករផងដែរ។ ពលករ ដែលបម្រើការងារតាមផ្ទះ ងាយទទួលរងគ្រោះ នៅពេលពួកគេបានរំលឹកជាប្រចាំចំពោះការបើក ប្រាក់បៀវត្សពីនិយោជករបស់ពួកគេ។ មាន ៧៨.៦ ភាគរយ បានរាយការណ៍ថា និយោជករបស់ ពួកគេមិនបានទទួលខុសត្រូវសេវាធានារ៉ាប់រងផ្នែកសុខភាពទេ និងមានការកាត់ប្រាក់ឈ្នួលទុក ឬ ការមិនបង់ប្រាក់ឈ្នួលដល់ពលករផងដែរ។

ពេលធ្វើការងារនៅក្នុងប្រទេសថៃ ពលករទេសន្តរប្រវេសន៍កម្ពុជាទាំងស្របច្បាប់ និងមិនស្របច្បាប់មានអារម្មណ៍ឯកោ ដោយសារឃ្លាតឆ្ងាយពីស្រុកកំណើត និងក្រុមគ្រួសារ និងសង្គមដែលពួកកំពុងរស់នៅ មិនអាចចែករំលែកជាមួយអ្នកដទៃ ឬស្វែងរកជំនួយផ្សេងទៀតបាន។ ពលករភាគច្រើនត្រូវការបណ្តាញផ្ទេរប្រាក់ត្រឡប់ និងការទំនាក់ទំនងជាមួយ ក្រុមគ្រួសាររបស់ពួកគេនៅឯស្រុកកំណើត។

ដោយសារតែ មានការលាយចម្រុះគ្នាជាច្រើនរវាងចំនួនពលករ ដែលធ្វើការដោយស្របច្បាប់ និងមិនស្របច្បាប់នៅក្នុងប្រទេសថៃ នៅពេលកន្លងទៅនេះ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតក្រុមការងារអន្តរក្រសួងដើម្បីចេញប័ណ្ណសម្គាល់ខ្លួន (CI) សម្រាប់ពលករកម្ពុជា ដែលមិនស្របច្បាប់ ឱ្យក្លាយជាស្របច្បាប់វិញ។[19]

## ២.៤. ការធ្វើទេសន្តរប្រវេសន៍ទៅសាធារណៈរដ្ឋកូរ៉េខាងត្បូង

នៅឆ្នាំ២០០៣ ប្រទេសកម្ពុជាបានបញ្ជូនពលករប្រហែល ៧៥៦ នាក់ ក្នុងមួយឆ្នាំ ទៅសាធារណៈរដ្ឋកូរ៉េខាងត្បូង តាមរយៈប្រព័ន្ធបណ្តុះបណ្តាលមួយ។ ប្រព័ន្ធនេះ អនុញ្ញាតឱ្យប្រជាជនកម្ពុជា ទៅធ្វើការនៅប្រទេសកូរ៉េក្នុងរយៈពេលខ្លីដើម្បីទទួលបានជំនាញថ្មីៗ ដែលពួកគេអាចប្រើប្រាស់នៅពេលត្រឡប់មកប្រទេសកម្ពុជាវិញ ដើម្បីរកការងារធ្វើ។ មានពលករ កម្ពុជាចំនួន ៣.៩៨៣ នាក់ ដែលក្នុងនោះមានស្ត្រីចំនួន ៩៥៥ នាក់ បាន និងកំពុងបម្រើការងារនៅប្រទេសកូរ៉េ។ ពួកគេទាំងអស់គឺជាពលករដែលធ្វើការដោយស្របច្បាប់ និងភាគច្រើនជាបុរស។[20]

[19] ទំព័រទី ១៤, ១៥, ចំណុច ៣.២, ទេសន្តរប្រវេសន៍ និងការអភិវឌ្ឍនៅកម្ពុជា, វិច្ឆកា២០០៩

[20] ទំព័រទី ១៥, ចំណុច ៣.៣, ទេសន្តរប្រវេសន៍ និងការអភិវឌ្ឍនៅកម្ពុជា, វិច្ឆកា២០០៩

### តារាងទី៧: ចំនួនពលករទេសន្តរប្រវេសន៍កម្ពុជាធ្វើការនៅប្រទេសកូរ៉េខាងត្បូង[21]

| ឆ្នាំ | ពលករ | | | ពោងចក្រ | | |
|---|---|---|---|---|---|---|
| | ទាំងពីរភេទ | បុរស | ស្ត្រី | ទាំងពីរភេទ | បុរស | ស្ត្រី |
| ២០០៣ | ៧៥៦ | ៦៣៨ | ១១៨ | ៧៥៦ | ៦៣៨ | ១៨ |
| ២០០៤ | ៦៧៤ | ៥១៩ | ១៥៥ | ៥៩៨ | ៤៤៣ | ១៥៥ |
| ២០០៥ | ៤៦៨ | ៤៣២ | ៣៦ | ៣៤១ | ៣០៥ | ៣៦ |
| ២០០៦ | ១.៥០១ | ១.៣៤១ | ៦១ | ១.៤៨៩ | ១.៣២៩ | ១៦០ |
| ២០០៧ | ៥៨៤ | ៤៩៩ | ៨៥ | ៤៣០ | ៤០៩ | ២១ |
| សរុប | ៣.៩៨៣ | ៣.៤២៩ | ៤៥៥ | ៣,៦១៤ | ៣.១២៤ | ៣៩០ |

[21] ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ឆ្នាំ២០០៨

# ជំពូកទី៣: ប្រាក់បញ្ញើត្រឡប់

## ៣.១. លំហូរប្រាក់បញ្ញើត្រឡប់ និងអត្ថប្រយោជន៍នៃទេសន្តរប្រវេសន៍អន្តរជាតិ

នៅក្នុងឆ្នាំ២០០៧ ប្រទេសឥណ្ឌា មិចស៊ីចកូ និងចិន គឺជាប្រទេសបី ដែលទទួលបានប្រាក់បញ្ញើត្រឡប់ច្រើនជាងគេ។ ចំនួនទឹកប្រាក់នេះ គឺតំណាងឱ្យស្មើតែមួយភាគបី នៃប្រាក់បញ្ញើដែលបានទទួលដោយប្រទេសកំពុងអភិវឌ្ឍន៍។ នៅក្នុងបញ្ជីដែលរាយនាមប្រទេសទាំង ១០ ក៏មានប្រទេសដែលមានប្រាក់ចំណូលខ្ពស់មួយចំនួនដែរ ដូចជា ប្រទេសបារាំង អេស្ប៉ាញ និងចក្រភពអង់គ្លេស ទទួលបានប្រាក់បញ្ញើត្រឡប់ភាគច្រើនពីបណ្តាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ផ្សេងទៀតពីក្នុងប្រទេសនៅសហគមន៍អឺរ៉ុប។ បើទោះបីជាយ៉ាងណា ប្រាក់បញ្ញើត្រឡប់សម្រាប់ប្រទេសទាំងនេះ គឺមានប្រហែលជា ០.៥ ភាគរយ ឬទាបជាងនៃផលទុនក្នុងស្រុករបស់ពួកគេនៅក្នុងឆ្នាំ ២០០៧។

រូបភាពទី២៖ ១០ប្រទេសដែលទទួលបានប្រាក់បញ្ញើត្រឡប់ច្រើនជាងគេ[22]




[22] Dilip Ratha, Sanket Mohapatra, K. M. Vijayalakshmi, Zhimei Xu: Migration and Development Brief 3, Development Prospects Group Migration and Remittances Team, November 29, 2007

ប្រទេសកម្ពុជា មិនទាន់មានបណ្តាញផ្ទេរប្រាក់បញ្ញើត្រឡប់ ជាផ្លូវការ និងការត្រួតពិនិត្យលំហូរប្រាក់បញ្ញើពីការធ្វើទេសន្តរប្រវេសន៍ទាំងនៅក្នុងស្រុក និងពីបរទេសនៅឡើយទេ។ ទិន្នន័យស្តីពីប្រាក់បញ្ញើត្រឡប់មានតិចតួច និងមិនសូវច្បាស់លាស់ទេ ព្រោះមានការលំបាកក្នុងការប្រមូល និងរាយការណ៍ព័ត៌មានទាំងនោះ។ ពលករទេសន្តរប្រវេសន៍ដែលធ្វើការនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ និងពលករដែលធ្វើការនៅក្នុងរោងចក្រ បានបញ្ជូនប្រាក់ត្រឡប់ទៅឱ្យក្រុមគ្រួសាររបស់ពួកគេ គិតជាមធ្យមជារៀងរាល់ ៣ ទៅ ៤ខែ។ កន្លងមកប្រព័ន្ធផ្ទេរប្រាក់បញ្ញើដែលពេញនិយមជាងគេ គឺការផ្ទេរប្រាក់តាមប្រព័ន្ធទូរស័ព្ទ (៦១ ភាគរយ) តាមសាច់ញាតិ (៣២ ភាគរយ) តាមអ្នកនាំសារ (៤ ភាគរយ) ដោយពលករខ្លួនឯង និងតាមធនាគាររបស់ក្រុមហ៊ុន និងផ្សេងៗ ទៀត។

រូបភាពទី៣៖ ប្រព័ន្ធផ្ទេរប្រាក់ពីប្រទេសថៃមកកម្ពុជា[23]




យោងតាមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT) បានធ្វើការប៉ាន់ប្រមាណអំពីប្រាក់បញ្ញើត្រឡប់ ដែលប្រទេសកម្ពុជាទទួលបានពីពលករ ទៅធ្វើការនៅប្រទេសកូរ៉េមានចំនួនទឹក

[23] Maltoni, 2006

ប្រាក់ប្រហែល ៤៨ លានដុល្លារអាមេរិក ដែលបានបញ្ជូនជារៀងរាល់ឆ្នាំ ទៅឱ្យក្រុមគ្រួសាររបស់ពលករ។ ពលករទទួលបានប្រាក់បៀវត្សប្រចាំខែមិនទាបជាងពី ៨០០ ដុល្លារ ទៅ ១.០០០ ដុល្លារអាមេរិកទេ។ នៅក្នុងរោងចក្រមួយចំនួនមានការធ្វើការបន្ថែមម៉ោងសម្រាប់ពលករដែលមានជំនាញធ្វើឱ្យពួកគេរកប្រាក់ចំណូលបានរហូតដល់ ២.០០០ ដុល្លារ ក្នុងមួយខែ។ ចំណែកឯពលករដែលទៅធ្វើការនៅប្រទេសម៉ាឡេស៊ីវិញ បានទទួលប្រាក់បៀវត្សប្រហែលជា ១៥០ ដុល្លារ ហើយប្រាក់បញ្ញើត្រឡប់ទៅក្រុមគ្រួសារសរុបប្រហែលជា ២២ លានដុល្លារក្នុងមួយឆ្នាំ។ សម្រាប់ពលករកម្ពុជា ដែលធ្វើនៅប្រទេសថៃ ពួកគេទទួលបានប្រាក់បៀវត្សប្រចាំខែប្រហែល ១៥០ ដុល្លារ និងប្រាក់បញ្ញើត្រឡប់ទៅក្រុមគ្រួសារសរុបប្រហែលជា ១៤ លានដុល្លារ ក្នុងមួយឆ្នាំ។

យោងតាមការប៉ានប្រមាណរបស់ធនាគារពិភពលោក (ឆ្នាំ២០០៩) បានបង្ហាញថា ប្រទេសកម្ពុជា បានទទួលប្រាក់បញ្ញើត្រឡប់ដែលទទួលបានពីការធ្វើទេសន្តរប្រវេសន៍អន្តរជាតិមានចំនួនទឹកប្រាក់ត្រឹមតែ ១២១ លានដុល្លារអាមេរិកប៉ុណ្ណោះ នៅឆ្នាំ២០០០ តែមានការកើនឡើងរហូតដល់ ៣៥៣ លានដុល្លារ នៅឆ្នាំ២០០៧។ ចំនួនទឹកប្រាក់នេះប្រហែលជា ៤.១ ភាគរយ នៃផលិតផលសរុបក្នុងស្រុក (GDP) ដែលជាកត្តាមួយចូលរួមនៅក្នុងការកាត់បន្ថយភាពក្រីក្រមួយផ្នែកនៅកម្ពុជាផងដែរ។[24]

រូបភាពទី៤៖ ១០ប្រទេសដែលទទួលបានប្រាក់បញ្ញើត្រឡប់ច្រើនជាងគេ[25]




[24] ទំព័រទី ១៦, ១៧, ១៨, ១៩ ចំណុច ៤.១, ទេសន្តរប្រវេសន៍ និងការអភិវឌ្ឍនៅកម្ពុជា, វិច្ឆកា ២០០៩

[25] ធនាគារពិភពលោក ឆ្នាំ២០០៩

## ៣.២. លំហូរប្រាក់បញ្ញើត្រឡប់ និងអត្ថប្រយោជន៍នៃទេសន្តរប្រវេសន៍ក្នុងប្រទេស

លទ្ធផលនៃការសិក្សាស្តីអំពីការធ្វើទេសន្តរប្រវេសន៍ពីទីជនបទ និងទីប្រជុំជន ដែលបានធ្វើឡើងដោយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ឆ្នាំ២០០៧ បានបង្ហាញថា ស្ថាប័នមីក្រូហិរញ្ញវត្ថុមិនបានដើរតួនាទីសំខាន់នៅក្នុងការបញ្ជូនប្រាក់បញ្ញើត្រឡប់ ទៅឱ្យក្រុមគ្រួសាររបស់ពលករទេសន្តរប្រវេសន៍ទេ។ នេះគឺដោយសារតែថ្លៃសេវាផ្ទេរប្រាក់ខ្ពស់ និងនីតិវិធីស្មុគស្មាញបើប្រៀបធៀបទៅនឹងការបញ្ជូនប្រាក់តាមប្រព័ន្ធមិនផ្លូវការ។ ប្រព័ន្ធមិនផ្លូវការក្នុងការបញ្ជូនប្រាក់ត្រឡប់ទៅក្រុមគ្រួសារ រួមមានតាមរយៈសាច់ញាតិដោយខ្លួនឯង ក្នុងអំឡុងពេលទៅលេងក្រុមគ្រួសារ តាមមិត្តភ័ក្តិ សមាជិកក្រុមគ្រួសារឡើងមកយកដោយផ្ទាល់ ឬផ្ញើតាមអ្នកស្រុកភូមិជាមួយ។ លើសពីនេះ បណ្តាញដែលពេញនិយមលឿន និងងាយស្រួល គឺការផ្ញើប្រាក់តាមតាក់ស៊ី និងតាមបណ្តាញសេវាទូរស័ព្ទ។

**តារាងទី៨: បណ្តាញប្រាក់បញ្ញើត្រឡប់សម្រាប់ការធ្វើទេសន្តរប្រវេសន៍ជនបទ និងទីប្រជុំជន[26]**

| ប្រភេទបណ្តាញប្រាក់បញ្ញើត្រឡប់ | ភាគរយ |
|---|---|
| សមាជិកក្រុមគ្រួសារឡើងមកយកដោយផ្ទាល់ | ២.០២ |
| ស្ថាប័នមីក្រូហិរញ្ញវត្ថុ | ៦.២៦ |
| បណ្តាញសេវាទូរស័ព្ទ | ៧.០៧ |
| តាក់ស៊ី | ៨.៨៩ |
| តាមមិត្តភ័ក្តិ | ២៤.៤៤ |
| ដោយខ្លួនឯង | ២៥.០៥ |
| សាច់ញាតិ | ២៦.២៦ |

ប្រាក់បញ្ញើ ដែលទទួលបានពីពលករទេសន្តរប្រវេសន៍ មិនត្រឹមតែផ្តល់ផលប្រយោជន៍សម្រាប់ពលករខ្លួនឯងទេ ថែមទាំងសម្រាប់ប្រទេស និងក្រុមគ្រួសាររបស់ពលករផងដែរ។ ប្រាក់

[26] វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍នៅកម្ពុជា ឆ្នាំ២០០៧

ចំណូលរបស់ពលករទេសន្តរប្រវេសន៍ ជួយគាំទ្រយ៉ាងសំខាន់ដល់ពលករខ្លួនឯង និងក្រុមគ្រួសារនៅឯស្រុកកំណើត។ យោងតាមការវាយតម្លៃអំពីភាពក្រីក្រដែលធ្វើឡើងដោយធនាគារពិភពលោកឆ្នាំ២០០៦ បានរកឃើញថា ១៣ ភាគរយ នៃក្រុមគ្រួសារនៅទីជនបទ បានទទួលប្រាក់បញ្ញើពីសមាជិកក្រុមគ្រួសារដែលធ្វើការនៅទីក្រុង និងតម្លៃនៃប្រាក់បញ្ញើទាំងអស់នោះ មានចំនួនតិចជាង ១០ ភាគរយនៃការប្រើប្រាស់របស់គ្រួសារគិតជាមធ្យម។

ការចូលរួមចំណែកហិរញ្ញវត្ថុរបស់ពលករទេសន្តរប្រវេសន៍ ចំពោះក្រុមគ្រួសារក្លាយជាកត្តាចម្បងសម្រាប់ការធ្វើបំលាស់ទីរបស់ពួកគេ។ ប្រាក់បញ្ញើរបស់ពលករទេសន្តរប្រវេសន៍ ជាផ្នែកមួយយ៉ាងសំខាន់ សម្រាប់ជួយបង្កើនប្រាក់ចំណូលក្រុមគ្រួសារ ឱ្យមានស្ថេរភាព។ តម្រូវការចាំបាច់សម្រាប់ប្រាក់បញ្ញើ គឺមានច្រើនយ៉ាងដូចជា ក្រុមគ្រួសាររបស់ពលករទេសន្តរប្រវេសន៍ ត្រូវការប្រាក់សម្រាប់ទិញសម្ភារ ឧបករណ៍កសិកម្ម ចំណាយទិញសម្ភារក្នុងផ្ទះ ទិញគ្រាប់ពូជ ជីគីមីកសិកម្ម បង់ថ្លៃសាលារៀនកូន ការចំណាយរស់នៅប្រចាំថ្ងៃ សងបំណុលដោយសារការមិនបានផល បន្ទាប់ពីទទួលរងគ្រោះមហន្តរាយ ចំណាយជួសជុលផ្ទះ និងវិនិយោគលើអាជីវកម្ម។

ជាការពិតណាស់ មានពលករទេសន្តរប្រវេសន៍មួយចំនួនតូច ដែលបានប្រើប្រាស់ប្រាក់ចំណូលសម្រាប់ខ្លួនឯងផ្ទាល់ ដូចជាការទិញសម្ភារថ្មី និងទាន់សម័យ អំឡុងពេលរស់នៅទីក្រុង។ ទោះជាយ៉ាងនេះក្តី ភាគច្រើននៃពលករទេសន្តរប្រវេសន៍ បានលើកឡើងថា ប្រាក់ចំណូលរបស់ពួកគេមួយផ្នែកធំ ត្រូវបានប្រើប្រាស់សម្រាប់ចំណាយផ្សេងៗ ក្នុងក្រុមគ្រួសារ។ ប្រាក់បញ្ញើត្រឡប់ត្រូវបានប្រើប្រាស់សំខាន់សម្រាប់ការទិញអាហារ។ លទ្ធផលនៃការស្រាវជ្រាវទាំងពីរ (ជាមួយពលករ និងក្រុមគ្រួសារ) បង្ហាញថា ការទិញទ្រព្យសកម្ម ផ្សេងទៀត ដូចជា ពូជស្រូវ ជី ដីស្រែ ឬត្រាក់ទ័រ គឺជាចំណាយសំខាន់ទាំងពីរ។ ចំណែកឯការចំណាយសង្គម ដូចជា ការចូលរួមការរៀបអាពាហ៍ពិពាហ៍ និងពិធីបុណ្យទានផ្សេងៗ គឺជាកត្តាសំខាន់ទីបី (នៅទីជនបទចំណាយទាំងអស់នេះកើតឡើងជាញឹកញាប់)។ ចំណាយមួយផ្សេងទៀតដែលចាត់ទុកថា មានប្រយោជន៍សម្រាប់រយៈពេលវែងគឺការបង់ថ្លៃសាលារៀន និងទិញសម្ភារសិក្សាជាប្រភេទចំណាយសំខាន់ទីបួន (លទ្ធផលស្រាវជ្រាវជាមួយពលករ) និងទីប្រាំ (លទ្ធស្រាវជ្រាវជាមួយគ្រួសារ) ដែលយោងតាមការស្រាវជ្រាវរបស់(វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ឆ្នាំ២០០៧)។

ប្រាក់បញ្ញើត្រឡប់ គឺជាប្រភពប្រាក់ចំណូលដ៏សំខាន់បំផុត និងទៀងទាត់ សម្រាប់ក្រុមគ្រួសាររបស់ពលករនៅក្នុងប្រទេស ជាពិសេសនៅទីជនបទ។ ប្រាក់បញ្ញើត្រឡប់របស់ពលករ ត្រូវបានចំណាយមួយផ្នែកសម្រាប់ការប្រើប្រាស់របស់ក្រុមគ្រួសារ និងមួយផ្នែកសម្រាប់សន្សំ និងវិនិយោគ ដូចជាប្រាក់ចំណូលផ្សេងៗ ទៀតផងដែរ។ ប្រាក់បញ្ញើដែលបានទទួលពីពលករទេសន្តរប្រវេសន៍ បានជួយធ្វើឱ្យលក្ខខណ្ឌហិរញ្ញវត្ថុរបស់ក្រុមគ្រួសារមានភាពប្រសើរឡើង។ ៧៦ ភាគរយនៃក្រុមគ្រួសារ របស់ពលករទទួលបានភាពល្អប្រសើរយ៉ាងខ្លាំង បន្ទាប់ពី គេមានសមាជិកក្រុមគ្រួសារ បានធ្វើបំលាស់ទីទៅកាន់ទីប្រជុំជន។ ចំណែកឯ ១៣ ភាគរយ ទៀតមានលក្ខណៈប្រសើរតែបន្តិចបន្តួចប៉ុណ្ណោះ។[27]

រូបភាពទី៥៖ ការផ្លាស់ប្តូរលក្ខខណ្ឌហិរញ្ញវត្ថុរបស់ក្រុមគ្រួសារពលករទេសន្តរប្រវេសន៍[28]




[27] ទំព័រទី ១៩, ២០, ២១, ចំណុច ៤.២, ទេសន្តរប្រវេសន៍ និងការអភិវឌ្ឍនៅកម្ពុជា, វិច្ឆកា ២០០៩

[28] វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍នៅកម្ពុជា ឆ្នាំ២០០៧

# សេចក្តីសន្និដ្ឋាន

ទេសន្តរប្រវេសន៍ គឺជាកត្តាមួយដ៏សំខាន់សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ និងជួយឱ្យពលករទេសន្តរប្រវេសន៍ និងក្រុមគ្រួសារពលករទាំងអស់ មានជីវភាពរស់នៅល្អប្រសើរជាងមុន។ ប្រាក់ចំណូលដែលពលករទេសន្តរប្រវេសន៍ ទទួលបានប្រាក់បៀវត្សខ្ពស់ ក៏ជាផ្នែកមួយជួយឱ្យប្រទេសជាតិមានការរីកចម្រើនផងដែរ។

ផ្ទុយទៅវិញ បើទោះជាពលរកទេសន្តរប្រវេសន៍ ទៅធ្វើការនៅក្រៅប្រទេស អាចស្វែងរកប្រាក់ចំណូលបានខ្ពស់ជាងនៅក្នុងប្រទេសក៏ដោយ ក៏មានពលករទេសន្តរប្រវេសន៍មួយចំនួនមិនចង់ទៅធ្វើការនៅបរទេសដែរ ព្រោះពួកគេនឹងត្រូវបង្ខំចិត្តបែកចេញពីឪពុកម្តាយ មិត្តភ័ក្តិ ប្តីប្រពន្ធ និងសង្សារ។ កត្តាមួយវិញទៀត គឺបណ្តាលមកពីការងារ នៅក្នុងប្រទេសមិនគ្រប់គ្រាន់ ប្រាក់បៀវត្សទាប លក្ខខណ្ឌការងារមិនល្អ មិនអាចផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃ និងក្រុមគ្រួសាររបស់ពួកគេបានគ្រប់គ្រាន់ ដូច្នេះទើបបណ្តាលឱ្យមានពលករទេសន្តរប្រវេសន៍ជាច្រើន បានចេញទៅធ្វើការនៅប្រទេសថៃ ម៉ាឡេស៊ី និងប្រទេសកូរ៉េខាងត្បូង ជារៀងរាល់ឆ្នាំ។

ទាំងនេះជាបញ្ហាដែលរាជរដ្ឋាភិបាលកម្ពុជា អង្គការជាតិ និងអន្តរជាតិ កំពុងតែមានការព្រួយបារម្ភយ៉ាងខ្លាំង ដោយសារតែ ប្រជាជនកម្ពុជាយ៉ាងច្រើនកុះករ បានសម្រុកចេញពីប្រទេស ទៅបរទេសដើម្បីស្វែងរកការងារគួរឱ្យកត់សម្គាល់ ដែលអាចធ្វើឱ្យប្រទេសកម្ពុជាខ្លួនឯង បាត់បង់នូវកម្លាំងពលកម្មសម្រាប់បម្រើការងារនៅក្នុងប្រទេស ជាពិសេស នៅក្នុងវិស័យកសិកម្ម។

# អនុសាសន៍

- ក្រុមការងារ ជាពិសេសក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី គប្បីពិនិត្យ និងបង្កើតឱ្យមានបែបបទ នីតិវិធីឱ្យបានច្បាស់លាស់ ដើម្បីគ្រប់គ្រងភាពចល័តរបស់ប្រជាពលរដ្ឋ និងគ្រប់គ្រងចំណាកស្រុកឱ្យមានប្រសិទ្ធភាព តាមរបៀបដែលងាយស្រួល និងអាចអនុវត្តបានទូទាំងប្រទេស

- កំណត់ចំនួនទីតាំច្រកចេញ និងសមត្ថកិច្ចទទួលខុសត្រូវជាក់លាក់

- កំណត់តួនាទីភារកិច្ចរបស់សមត្ថកិច្ចគ្រប់ផ្នែកដែលត្រូវឯកភាពគ្នា ធ្វើការងារឱ្យរលូន តាំងពីមូលដ្ឋាន ប្រភពរហូតដល់ច្រកចេញ ចូល និងនៅកន្លែងធ្វើការងារ និងនៅពេលត្រឡប់មកវិញ

- ខេត្តនីមួយៗ គួរមានក្រុមដែលធ្វើការងារជាប្រព័ន្ធ ទទួលខុសត្រូវលើទិន្នន័យជាក់លាក់ សម្រាប់ប្រើប្រាស់ជាព័ត៌មានដល់សាធារណជន អំពីតម្រូវការការងារ និងកម្លាំងពលកម្ម ប្រភេទការងារ លក្ខខណ្ឌជ្រើសរើស រយៈពេលការងារ ប្រាក់បៀវត្ស ការចុះបញ្ជីពលករដែលត្រូវការការងារ នីតិវិធីក្នុងការបញ្ជូនចេញចូល និងរបៀបទំនាក់ទនងគ្នា ជាមួយក្រុមហុន ឬកន្លែងផ្តល់ការងារឱ្យបាន ច្បាស់លាស់

- ក្រុមហ៊ុនដែលត្រូវការពលករក្នុងស្រុក និងក្រៅប្រទេស ត្រូវផ្តល់ព័ត៌មានអំពីលក្ខខណ្ឌការងារ ការធានាសុវត្ថិភាព កម្រិតប្រាក់បៀវត្ស ដោយសហការផ្សព្វផ្សាយជាមួយអាជ្ញាធរមូលដ្ឋានឱ្យបានទូលំទូលាយ

- ចាំបាច់ត្រូវចរចាឱ្យមានការឯកភាពគ្នាជាមួយភាគីបរទេស ដែលមានពលករមិនស្របច្បាប់ ដើម្បីរកនីតិវិធីទទួលស្គាល់ភាពស្របច្បាប់របស់ពលករ ដែលត្រូវទៅធ្វើការ ឬកំពុងធ្វើការក្នុងប្រទេសនោះ។

- បន្តអនុវត្តនីតិវិធី សម្រាប់ទំនាក់ទំនងប្រទេសពាក់ព័ន្ធ។[29]

[29] ទំព័រទី ១០, ១១, អនុសាសន៍, បទបង្ហាញអំពីលទ្ធផលនៃការសិក្សាស្រាវជ្រាវអំពីទេសន្តរប្រវេសន៍នៅកម្ពុជា

- អ្វីដែលប្រសើរបំផុតសម្រាប់ពលករ រាជរដ្ឋាភិបាលកម្ពុជា គួរមានយុទ្ធសាស្ត្រថ្មីៗ ដើម្បីឱ្យអ្នកវិនិយោគបរទេស ចូលមកវិយោគកាន់តែច្រើន។ ជាពិសេស ក្រុមអ្នកមានប្រាក់(ឧញ្ញា) ក្នុងប្រទេសកម្ពុជា គួរបង្កើតការវិនិយោគឱ្យបានច្រើន ដើម្បីជួយលើសស្ទួយសេដ្ឋកិច្ចជាតិ និងផ្តល់ឱកាសការងារដល់ពលករក្នុងស្រុក។

# គន្ថនិទ្ទេស


- គោលនយោបាយ និងការគ្រប់គ្រងពលកម្មទេសន្តរប្រវេសន៍ (ម៉ូឌុលបណ្តុះបណ្តាល)
- ទេសន្តរប្រវេសន៍ និងការអភិវឌ្ឍនៅកម្ពុជា (ឆ្នាំ២០០៩)
- បទបង្ហាញអំពីលទ្ធផលនៃការសិក្សាស្រាវជ្រាវអំពីទេសន្តរប្រវេសន៍នៅកម្ពុជា
- វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ: ជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជា ២០០៨
- វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍នៅកម្ពុជា ឆ្នាំ២០០៧
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០០៨
- Dilip Ratha, Sanket Mohapatra, K. M. Vijayalakshmi, Zhimei Xu: Migration and Development Brief 3, Development Prospects Group Migration and Remittances Team, November 29, 2007
- Maltoni, 2006
- World Bank (2007): Sharing Growth: equity and development in Cambodia, Phnom Penh, Cambodia.
- World Bank (2008): Urban Development and Cambodia. http://web.worldbank.org. View June 10, 2008.
- World Bank (2009): Migration and Remittances Factbook is compiled by Dilip Ratha and Zhimei Xu, www.worldbank.org/prospects/migrationandremittances.
- World Bank (2007): Migration and Development Briefs, www.worldbank.org/prospects/migrationandremittances.

# ឧបសម្ព័ន្ធ

## របាយការណ៍បូកសរុបលទ្ធផលសិក្ខាសិលាថ្នាក់ជាតិ
## ស្តីពី
## ការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារកម្ពុជា

សិក្ខាសាលាថ្នាក់ជាតិ ស្តីពីការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារកម្ពុជា បានប្រព្រឹត្តទៅអស់រយៈ ពេលប្រព្រឹត្តទៅរយៈពេលបីថ្ងៃគឺពីថ្ងៃទី ២៦ រហូតដល់ ២៨ ខែមីនា ឆ្នាំ ២០១៣ ដោយមានការចូលរួមពីសមាជិកសភា សមាជិករាជរដ្ឋាភិបាលដែលអញ្ជើញមកពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងកិច្ចការនារី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទីភ្នាក់ងារអង្គការសហប្រជាជាតិ ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសម៉ាឡេស៊ី ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសថៃ អគ្គស្នងការរងនគរបាលជាតិ អគ្គបញ្ជាការដ្ឋាន ក្រសួងការពារជាតិ អភិបាល អភិបាលរង ស្នងការ ស្នងការរង អភិបាលស្រុក មេឃុំ ចៅសង្កាត់ ទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ តំណាងក្រុមហ៊ុន បងប្អូនពលករ ពលការិនីសរុបប្រមាណជិត ៤០០ នាក់ ។

កិច្ចប្រជុំ បានដំណើរការតាមការគ្រោងទុកដោយរលូន ។ ក្នុងកម្មវិធីបើក បន្ទាប់ពីមានមតិស្វាគមន៍ និងរបាយការណ៍សង្ខេបស្តីពីស្ថានភាពទេសន្តរប្រវេសន៍ និងគោលបំណងនៃកិច្ចប្រជុំរួចមក លោកស្រី ជេណា ហូលីដេ អ្នកសម្របសម្រួលកម្មវិធីពីអង្គការសហប្រជាជាតិដើម្បីការលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់ភាពអង់អាចដល់ស្ត្រី (UN Women) បានធ្វើចំណាប់អារម្មណ៍របស់ក្នុងនាមជាតំណាងទីភ្នាក់ងារអង្គការសហប្រជាជាតិ និងអង្គការដៃគូអភិវឌ្ឍន៍ ។ ឯកឧត្តម វង សូត រដ្ឋមន្ត្រីក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាអនុប្រធានគណៈកម្មាធិការជាតិ ប.ជ.រ.ព.ភ បានផ្តល់កិត្តិយសអញ្ជើញជាអធិបតី ក្នុងពិធីបើក ។

អង្គសិក្ខាសាលា បានឯកភាពគ្នា ក្នុងការពិភាក្សា ក្នុងគោលគំនិតរកឲ្យឃើញបញ្ហាពិត និងភាពខ្វះចន្លោះដែលចាំបាច់ដែលត្រូវបំពេញបន្ថែម គន្លឹះ និងមិនមែនជាការជែកញែករកកំហុសស្ថាប័ន ឬអង្គភាពណា ឬជាការប្រកួតប្រជែងគ្នាដើម្បីជាគុណសម្បត្តិក្នុងការបំពេញភារកិច្ចឡើយ តែគឺដើម្បីរកការឯកភាពគ្នាជាទស្សនៈ ដើម្បីឈានឆ្ពោះទៅការរៀបចំការអនុវត្តបន្តឲ្យចំទិសដៅ ។

សិក្ខាសាលា បានរៀបចំជាវេទិកាចំនួន៥ ដើម្បីប្រមូលផ្តុំ បញ្ញាញាណពីគ្រប់អ្នកជំនាញពាក់ព័ន្ធ មកពីក្រសួងស្ថាប័ន វិទ្យាស្ថានស្រាវជ្រាវ សមត្ថកិច្ចពាក់ព័ន្ធក្នុងនគរបាលជាតិ កងកម្លាំងយោធា អាជ្ញាធរខេត្ត អង្គការមិនមែនរដ្ឋាភិបាល សហជីព និងពលករ ពលការិនី ដើម្បីចែករំលែកពត៌មាន ទស្សនៈ បទពិសោធន៍ ទាំងឡាយដើម្បីមានមូលដ្ឋានក្នុងការសន្និដ្ឋានថាតើត្រូវធ្វើដូចម្តេចដើម្បីអាចពង្រឹងការគ្រប់គ្រងប្រជាពលរដ្ឋបានល្អប្រសើរ ។

គោលបំណងរួមសំខាន់បំផុត គឺបង្កើតបរិយាកាសល្អប្រសើរ ដើម្បីផ្តល់ជម្រើសដល់ប្រជាពលរដ្ឋ ដើម្បី ៖ **ធ្វើការក្នុងស្រុកក៏ល្អប្រសើរ បើចេញទៅធ្វើការងារក្រៅប្រទេសក៏មានសុវត្ថិភាព ។**

វេទិកាចំនួន ៥ បានត្រូវរៀបចំឡើង ដើម្បីជូនអ្នកដឹកនាំ អ្នកស្រាវជ្រាវ អ្នកបច្ចេកទេសតាមបណ្តាក្រសួងស្ថាប័ន អង្គការសង្គមស៊ីវិល សហជីពកម្មករ និងពលករ ពលការិនី បានចែករំលែកពត៌មាន កិច្ចខិតខំប្រឹងប្រែង

ទិន្នន័យ ទស្សនៈ និងបទពិសោធន៍ ជូនអង្គសិក្ខាសាលាបានជ្រាប និងស្រាយបំភ្លឺលើចំណុចដែលស្រពិចស្រពិល និងបំពេញបន្ថែមដោយសមាជិកដទៃទៀត ។ ខ្លឹមសារនៃវេទិកាទាំង ៥ គឺ៖

វេទិកាទី១ ស្តីពីឱកាសការងារ និងមុខរបរក្នុងស្រុក

វេទិកាទី២ ស្តីពី ឱកាសនិងទីផ្សារការងារនៅក្រៅប្រទេសតាមប្រព័ន្ធផ្លូវការនិងមិនផ្លូវការ

វេទិកាទី៣ ស្តីពី បទអន្តោគមន៍របស់ខេត្តសំចតនិងជាប់ព្រំដែន

វេទិកាទី៤ ស្តីពី បទពិសោធន៍នៅក្នុងការគ្រប់គ្រងលំហូរពលករ

វេទិកាទី៥ ស្តីពី អនុសាសន៍ទាក់ទងកិច្ចការពារ និងលើកកម្ពស់សិទ្ធិពលករនៅឆ្នាំ២០១២ និងទិសដៅបន្ត ។

បន្ទាប់មក អង្គសិក្ខាសាលា បានបែងចែកជាក្រុមពិភាក្សា ចំនួន ៦ក្រុម ដែលផ្តោតការយកចិត្តទុកដាក់លើ ៖

១. ការកំណត់នីតិវិធី និងស្ថាប័នពាក់ព័ន្ធ សម្រាប់ការគ្រប់គ្រងទេសន្តរប្រវេសន៍

ក. ដែលបាន និងកំពុងឆ្លងដែន តាមប្រព័ន្ធមិនផ្លូវការ ចូលទៅរកការងារធ្វើក្នុងប្រទេសថៃ ទាំងរយៈពេលយូរ ទាំងរយៈពេលខ្លី

ខ. ដែលត្រូវបានបញ្ជូនតាមកិច្ចព្រមព្រៀងតាមប្រព័ន្ធផ្លូវការ ទៅប្រទេសថៃ ប្រទេសម៉ាលេស៊ី និងប្រទេសផ្សេងទៀត ។

២. វិធានការការពារសិទ្ធិ និងផលប្រយោជន៍របស់ពលករ ពលការិនី នៅក្រៅប្រទេស

ក. ដើម្បីបញ្ចៀសបញ្ហារំលោភបំពានសិទ្ធិ និងផលប្រយោជន៍ពលករ ពលការិនី

ខ. ដើម្បីដោះស្រាយ ករណីរំលោភបំពាន ដែលបានកើតឡើងលើពលករ ពលការិនី

៣. វិធានការការពារសិទ្ធិ និងផលប្រយោជន៍របស់ពលករ ពលការិនី នៅក្នុងស្រុក

ក. ដើម្បីបញ្ចៀសបញ្ហារំលោភបំពានសិទ្ធិ និងផលប្រយោជន៍ពលករ ពលការិនី

ខ. ដើម្បីដោះស្រាយ ករណីរំលោភបំពាន ដែលបានកើតឡើងលើពលករ ពលការិនី ។

៤. ការកសាងសមត្ថភាពរបស់ពលករ

ក. ចំពោះមុខ

ខ. ជាយុទ្ធសាស្ត្រ ក្នុងរយៈពេលវែង

៥. ការលើកកម្ពស់បរិយាកាសការងារសមស្របសម្រាប់ឱកាសការងារ និងមុខរបរក្នុងស្រុក ធ្វើដូចម្តេច ទើបអាចទាក់ទាញចំណាប់ចំណូលចិត្តពលករ ពលការិនី ឲ្យរីករាយ និងនឹងនចិត្ត ក្នុងការចាប់យកការងារ ឬមុខរបរ នៅក្នុងស្រុក

ក. ក្នុងប្រព័ន្ធសេដ្ឋកិច្ចរៀបរយ (រោងចក្រ សហគ្រាស ក្រុមហ៊ុន ....)

ខ. ក្នុងប្រព័ន្ធសេដ្ឋកិច្ចមិនរៀបរយ (ក្នុងវិស័យសហគ្រាសឯកជន លក់ដូរ ផលិត ចិញ្ចឹម ដាំដុះ ..)

៦. វិធានការជាក់លាក់សម្រាប់ការពារពលករទេសន្តរប្រវេសន៍ជាស្ត្រី

ក. ប្រភេទនៃភាពរងគ្រោះ ដែលតែងតែកើតមានលើស្ត្រី

ខ. វិធានការសមស្របដែលអាចបង្ការភាពរងគ្រោះ លើពលការិនី

គ. វិធានការក្នុងការការពារពលការិនី នៅពេល និងក្រោយពេលមានភាពរងគ្រោះ

នៅក្នុងវេទិកាទាំងប្រាំ និងការពិភាក្សាតាមក្រុមទាំង ៦ អង្គសិក្ខាសាលាបានបើកឱកាសយ៉ាងទូលំទូលាយដល់ វាគ្មិនឲ្យបញ្ចេញមតិដោយបើកចំហរ ឥតលាក់លៀម មិនមានការទប់ស្កាត់ ដែលឆ្លុះបញ្ចាំងពីទស្សនៈ ដែលដូចគ្នាខ្លះនិង

ខុសគ្នាខ្លះ ចំពោះការវិភាគទៅលើបញ្ហា និងការវាយតម្លៃទៅលើការអនុវត្តរបស់ស្ថាប័ន ។ តែទោះបីជាយ៉ាងនេះក្តី ទាំងវាគ្មិន ទាំងសមាជិកនៃអង្គសិក្ខាសាលា បានឯកភាពគ្នាជាទស្សនៈថា៖

- លំហូរទេសន្តរប្រវេសន៍ គឺជាចរន្តធម្មជាតិ ដែលមិនអាចបញ្ឈប់បាន ។ មនុស្សក្មេង ចាស់ ប្រុស ស្រី មានសេចក្តីត្រូវការ និងបំណងប្រាថ្នាមិនចេះចប់ សម្រាប់ការរស់នៅ ដែលចង់ឲ្យមានភាពដែលកាន់តែប្រសើរឡើង ។ បើមានឱកាស មនុស្សទាំងឡាយ នឹងព្យាយាមសាកល្បងចាប់យកឱកាសនោះ ទោះបីជាការសាក ល្បងនេះ ស្ថិតក្នុងលក្ខខ័ណ្ឌខុសគ្នា ដែលនាំឲ្យមានលទ្ធផលខុសគ្នាក៏ដោយ ។
- ទោះបីជាយ៉ាងនេះក្តី ក៏ការធ្វើទេសន្តរប្រវេសន៍នេះ ត្រូវតែស្ថិតក្រោមការគ្រប់គ្រងមួយដែលច្បាស់លាស់ ទាំងក្នុងប្រព័ន្ធស្របច្បាប់ដែលមានបច្ចុប្បន្ន ទាំងក្រុមជនទេសន្តរប្រវេសន៍ ដែលព្យាយាមទៅតាមប្រព័ន្ធមិនផ្លូវការ និងទាំងអ្នកដែលត្រៀមចេញទៅបន្តទៀត ។
- បញ្ហាទេសន្តរប្រវេសន៍នេះ គឺពាក់ព័ន្ធដល់ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន និងអង្គភាពសមត្ថកិច្ចនានា ទាំងអ្នកផ្តល់សេវាផ្ទាល់ ទាំងអ្នកដែលធ្វើការជាមួយប្រជាពលរដ្ឋក្នុងវិស័យពាក់ព័ន្ធដទៃទៀត ដែលចាំបាច់ត្រូវរួមគ្នាដោះស្រាយ និងទទួលស្គាល់នូវបញ្ហា និងដំណោះស្រាយទាំងនោះ ។
- រាជរដ្ឋាភិបាល ដែលរួមមានទាំង អាជ្ញាធរមូលដ្ឋាន សមត្ថកិច្ចគ្រប់ផ្នែក ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានកាតព្វកិច្ច ចាំបាច់ត្រូវរិះរកគ្រប់វិធានការ និងវិធីសាស្រ្ត សម្រាប់ផ្តល់នូវការសម្របសម្រួល បង្កលក្ខណៈមានទាំងការដាក់ចេញនូវគោលនយោបាយ យន្តការ និងការអនុវត្ត ដែលមានប្រសិទ្ធភាព ដើម្បីឆ្លើយតបទៅនឹងបំណងប្រាថ្នាសមស្របរបស់ប្រជាពលរដ្ឋ ។ ទន្ទឹមនឹងនោះ វិធានការក្នុងការគ្រប់គ្រងសភាពការណ៍ និងការគ្រប់គ្រងប្រជាពលរដ្ឋ នៅគ្រប់ស្ថានភាព គឺជាភាពចាំបាច់មិនអាចខ្វះបាន ។
- កន្លងមក គ្រប់ក្រសួង ស្ថាប័ន គ្រប់វិស័យ គ្រប់កម្រិត ទាំងនៅក្នុងប្រទេស ទាំងនៅក្រៅប្រទេស បានខិតខំបំពេញភារកិច្ចតាមមុខសញ្ញារៀងៗខ្លួន តែកិច្ចការទាំងអស់នោះ នៅដាច់ដាក់ងំៗ មិនទាន់មានភាពរលូន និងស៊ីសង្វាក់គ្នាឲ្យក្លាយជាសំណាញ់សុវត្ថិភាព និងមានលក្ខណៈពេញលេញ អាចធានាដល់ការគ្រប់គ្រងភាពចល័ត និងភាពរងគ្រោះរបស់ប្រជាពលរដ្ឋ នៅគ្រប់តំណាក់កាលនៃទេសន្តរប្រវេសន៍បានឡើយ ។
- ភាពមិនប្រទាក់ក្រឡា និងកង្វះកិច្ចសហការនេះ ត្រូវបានជនដែលឆ្លៀតឱកាស កេងចំណេញ និងបង្កភាពស្មុគស្មាញដល់សមត្ថកិច្ច និងភាពរងគ្រោះដល់ពលករ ។
- មិនទាន់ប្រើប្រាស់អស់នូវសក្តានុពលនៃផ្នែកពាក់ព័ន្ធ រួមមានអង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល ផ្នែកឯកជន សហជីព ដែលនៅជិតបំផុតជាមួយពលករ ដែលអាចប្រើប្រាស់តួនាទីខ្លួនដើម្បីការពារផលប្រយោជន៍ដល់ពលករ និងប្រជាពលរដ្ឋ ដោយចូលរួមក្នុងការផ្សព្វផ្សាយគោលនយោបាយ និងជម្រុញការអនុវត្តច្បាប់ និងជួយរកវិធានការក្នុងការផ្តល់កិច្ចសហការជាមួយរដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋ ។
- ទោះបីជាយ៉ាងនេះក្តី ក៏សមាជិកនៃអង្គសិក្ខាសាលា បានទទួលស្គាល់ថា កម្ពុជា មានច្បាប់ និងគោលនយោបាយជាតិដែលល្អប្រសើរ មានការប្តេជ្ញាចិត្តក្នុងការអនុវត្តនូវរាល់បទដ្ឋានគតិយុត្តិ និងឧបករណ៍ច្បាប់អន្តរជាតិទាំងឡាយ ដែលពាក់ព័ន្ធ និងខិតខំព្យាយាមធ្វើឲ្យសម្រេច ។
- ទទួលស្គាល់ការ វិធានការ និងនីតិវិធីដែលមាន និងអនុវត្តកន្លងមក នៅមិនទាន់គ្រប់គ្រាន់សម្រាប់ការគ្រប់គ្រងលំហូរពលករ និងធានាបាននូវការការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ពលករបាននៅឡើយ ដែលចាំបាច់ត្រូវពិនិត្យ និងបំពេញបន្ថែមឲ្យបានគ្រប់គ្រាន់ និងកំណត់តួនាទី

របស់សមត្ថកិច្ច និងស្ថាប័នពាក់ព័ន្ធឲ្យបានច្បាស់ ក្នុងការទទួលខុសត្រូវដោយឆន្ទការដែលមានភាពប្រទាក់ក្រឡាគ្នា និងសហការល្អ ។

- ទាំងពលករ ទាំងនិយោជក ទាំងក្រុមហ៊ុន ទាំងមន្ត្រីពាក់ព័ន្ធ សុទ្ធតែមានអ្នកដែលមានចរិតល្អត្រឹមត្រូវ មានគុណធម៌ តែក៏មានអ្នកដែលឆ្លៀតឱកាសដើម្បីកេងចំណេញ លើសភាពការណ៍ដែលគប្បីបែងចែកឲ្យបានច្បាស់ និងដាក់វិធានការឲ្យចំទិសដៅ
-

ទន្ទឹមនឹងនោះ អង្គសិក្ខាសាលាបាន លើកជាសំណូមពរ និងទស្សនៈមួយចំនួនដូចខាងក្រោម ៖

- ផ្សព្វផ្សាយឲ្យបានទូលំទូលាយ ពាក្យស្លោក ៖ ធ្វើការក្នុងស្រុកក៏ល្អប្រសើរ បើចេញទៅធ្វើការងារក្រៅប្រទេសក៏មានសុវត្ថិភាព និងជម្រុញអនុវត្តឲ្យបានល្អប្រសើរ
- ពិនិត្យឡើងវិញនិងវាយតម្លៃឲ្យបានត្រឹមត្រូវចំពោះ: ក្រុមហ៊ុនដែលអនុវត្តបានល្អតាមលក្ខខ័ណ្ឌកំណត់ និងគោលការច្បាប់ គួរត្រូវបានលើកទឹកចិត្ត ឯក្រុមហ៊ុនណាដែលមិនអនុវត្តត្រឹមត្រូវ កេងចំណេញ និងមានបំណងទុច្ចរិត គួរត្រូវបានផ្តន្ទាទោស
- ពង្រឹងកិច្ចសហការល្អជាអន្តរស្ថាប័ន ដើម្បីពង្រឹងការគ្រប់គ្រងតាមច្រករបៀង
- បង្កើនការផ្សព្វផ្សាយអំពីផលវិបាកនៃចំណាកស្រុកដោយប្រថុយប្រថាន មិនមានការធានាផ្នែកច្បាប់
- ពង្រឹង និងពង្រីកការអភិវឌ្ឍន៍មូលដ្ឋាន ពង្រីកការចូលរួមពីប្រជាពលរដ្ឋ ក្នុងការរៀបចំ និងអនុវត្តផែនការវិនិយោគឃុំសង្កាត់ ដែលឆ្លើយតបទៅនឹងបំណងប្រាថ្នា និងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ
- ពង្រីកឱកាសការងារ ពង្រីកការអនុវត្តលក្ខខ័ណ្ឌការងារល្អ និងកសាងបរិស្ថានការងារល្អ ក្នុងស្រុក និងតាមបណ្តាខេត្ត ព្រមទាំងពង្រីកការផ្សព្វផ្សាយពត៌មានជាក់លាក់អំពីទីផ្សារការងារក្នុងស្រុកឲ្យបានទូលំទូលាយ និងឲ្យដល់ប្រជាពលរដ្ឋ ដើម្បីជាជម្រើស និងអាចវិលត្រឡប់មកធ្វើការងារក្នុងស្រុកវិញ
- មានតម្រូវការក្នុងការបង្កើតការិយាល័យច្រកចេញចូលតែមួយ សម្រាប់សេវាការងារកម្ពុ ដើម្បីផ្តល់សេវាជាកញ្ចប់ កាត់បន្ថយភាពសាំញ៉ាំនៃការបំពេញបែបបទ នីតិវិធីក្នុងការចុះឈ្មោះ ការផ្តល់ឯកសារផ្លូវច្បាប់ (រួមទាំងលិខិតឆ្លងដែន) និងរកការងារជូនពលករ ដែលជា ដែលមានទំនាក់ទំនងគ្នាជាមួយមណ្ឌលសេវាការងាររបស់ថៃ និងជួយសម្រួលដល់ការផ្តល់សេវា ឲ្យនៅជិតប្រជាពលរដ្ឋ ប្រើរយៈពេលខ្លីបំផុត និងមានតម្លៃថោក និងកាត់បន្ថយសេវាក្រៅផ្លូវការ ជាពិសេស ឈ្មួញកណ្តាល
- ស្នើឲ្យមានការពិនិត្យលទ្ធភាពក្នុងការកាត់បន្ថយការកាត់តម្លៃសេវាពីពលករ ពី១០ខែ មកត្រឹម ៦ខែយ៉ាងច្រើន
- សូមរាជរដ្ឋាភិបាល ពិនិត្យលទ្ធភាពក្នុងការរៀបចំការិយាល័យដោយឡែកសម្រាប់ការផ្តល់លិខិតឆ្លងដែនសម្រាប់ពលករដែលត្រូវចេញទៅធ្វើការក្រៅប្រទេសដោយស្របច្បាប់
- ពិនិត្យលទ្ធភាពក្នុងការដាក់បញ្ចូល អ្នកធ្វើការងារតាមផ្ទះ ដែលភាគច្រើនជាស្ត្រី ដោយគិតអំពីលក្ខខ័ណ្ឌការងារ សុវត្ថិភាព និងសុខភាព ។
- ស្នើពិនិត្តលទ្ធភាពក្នុងការចុះហត្ថលេខា និងផ្តល់សច្ចាប័នលើអនុសញ្ញារបស់អង្គការការងារអន្តរជាតិ លេខ ១៨៩ ស្តីពីការងារសមរម្យ សម្រាប់អ្នកធ្វើការងារតាមផ្ទះ និងអនុសញ្ញា លេខ

.....ស្តីពីការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ ដែលរាជរដ្ឋាភិបាលកម្ពុជា បានចុះហត្ថលេខានៅឆ្នាំ២០០៤។

- ជំរុញ**កិច្ចសហការជាមួយ**ប្រទេសទទួល **ឲ្យ** អនុវត្តច្បាប់ការងារ **ដែល**គ្របដណ្តប់ដល់ពលករ **បរទេស ជាពិសេសពលករ**កម្ពុជា
- ពិនិត្យឡើងវិញនូវអនុស្សរណៈយោគយល់គ្នារវាងប្រទេសកម្ពុជានិងប្រទេសថៃ **ស្តីពីការប្រើប្រាស់ពលករទេសន្តរប្រវេសន៍** និងពង្រឹងការអនុវត្តអនុស្សរណៈនេះ។
- បញ្ចូលទេសន្តរប្រវេសន៍ការងារទៅក្នុងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ៥ឆ្នាំ ២០១៤-២០១៨ (NSDP)និងការវិភាជន៍ថវិកាជាតិសំរាប់ទេសន្តរប្រវេសន៍។
- **ស្នើពិនិត្យលទ្ធភាពក្នុងការ**រៀបចំការិយាល័យសំរាប់ធ្វើលិខិតឆ្លងដែននៅតាមខេត្តសំខាន់ៗជាប់ព្រំដែន **និងស្នើឲ្យមានការិយាល័យពិសេស** សំរាប់**ផ្តល់លិខិតឆ្លងដែនជូន**ពលករ**ដែលត្រូវទៅធ្វើការដោយស្របច្បាប់** ។
- ពង្រឹងកិច្ចសហការនិងការសម្របសម្រួល ជាមួយស្ថាប័នដែលពាក់ព័ន្ធ ជាពិសេសក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ ស្ថានទូតកម្ពុជានៅប្រទេសទទួល នៅក្នុងការលើកកំពស់និងកិច្ចការពារពលករចាប់ពីមុនពេលចេញដំណើររហូតត្រលប់មកវិញ។
- ក្រុមការងារទេសន្តរប្រវេសន៍ដែលជាយន្តការអន្តរក្រសួង ត្រូវសម្របសម្រួល និងត្រួតពិនិត្យតាមដានទៅលើការអនុវត្តច្បាប់និងគោលនយោបាយដែលពាក់ព័ន្ធទេសន្តរប្រវេសន៍ និងធ្វើអនុសាសន៍ជូនប្រធានគណៈកម្មាធិការជាតិនិងប្រមុខរដ្ឋាភិបាល។
- ត្រូវរៀបចំឧបករណ៍សំរាប់ការត្រួតពិនិត្យទីភ្នាក់ងារជ្រើសរើសពលករ ចាប់តាំងពីជ្រើសរើស ការបណ្តុះបណ្តាល ការបញ្ជូន និងសេវាគាំទ្រពលករ។
- ទីភ្នាក់ងារជ្រើសរើសពលករត្រូវចុះត្រួតពិនិត្យពលករនៅប្រទេសទទួល ឲ្យបានទៀងទាត់ និងគ្រប់គ្រងទិន្នន័យពលករឲ្យបានច្បាស់លាស់ ទាំងបញ្ជូនទៅនិងពេលត្រលប់មកវិញ។
- ទីភ្នាក់ងារជ្រើសរើសពលករត្រូវអនុវត្តកម្មវិធីបណ្តុះបណ្តាលច្បាស់លាស់មុនពេលចេញដំណើរ ជាពិសេសការបណ្តុះបណ្តាលសំរាប់ពលករជាស្ត្រី។
- ទីភ្នាក់ងារជ្រើសរើសពលករត្រូវបង្ហាញព័ត៌មានឲ្យបានច្បាស់លាស់ទាក់ទងឯកសារនិងការចំណាយសំរាប់ការធ្វើទេសន្តរប្រវេសន៍ដល់ពលករនិងសាធារណៈជន។
- រៀបចំកិច្ចព្រមព្រៀងជាមួយស្ថាប័នហិរញ្ញវត្ថុនៅក្នុងការបញ្ជូនប្រាក់បញ្ញើសំរាប់ពលករ ដែលមានការចំណាយទាបសំរាប់ការបញ្ជូន។
- រៀបចំយន្តការ និងនិតិវិធីគ្រប់គ្រង និងបង្កលក្ខណៈងាយស្រួល ដល់ពលករតាមរដូវការរកការងារធ្វើជាពិសេសនៅប្រទេសថៃ។

០ ពង្រឹងយន្តការ**សម្រាប់ទទួលការតវ៉ា** និងការផ្តល់សេវាទាន់ពេល សំរាប់ជនរងគ្រោះនិងធានាឲ្យបាននូវការទទួលបានយុត្តិធម៌សម្រាប់ពលករទេសន្តរប្រវេសន៍ **ដោយជម្រុញការផ្តន្ទាទោសជនល្មើស** ។

គណៈអធិបតីជាទីគោរព អង្គសិក្ខាសាលាទាំមូលជាទីគោរពរាប់អាន

ខាងលើនេះ គឺជាលទ្ធផលនៃការពិភាក្សាក្នុងរយៈពេលនៃសិក្ខាសាលា ដែលពិតជាមិនបាគ្រប់ជ្រុងជ្រោយ និងមិនគ្របដណ្តប់ទៅគ្រប់ទិដ្ឋភាពទាំងអស់នៃសង្គម ដែលជះឥទ្ធិពលដល់ការធ្វើទេសន្តរប្រវេសន៍ឡើយ ។ តែទោះបីជាយ៉ាងនេះក្តី ក៏យើងខ្ញុំសង្ឃឹមថា គណៈអធិបតី សមាជិក សមាជិកានៃអង្គសិក្ខាសាលាទទួលបាននូវព័ត៌មានគន្លឹះ និងឈានដល់ការឯកភាពគ្នាជាទស្សនៈ ដូចបានជម្រាបជូនខាងលើ ដែល នឹងគោរពស្នើសុំ មតិដឹកនាំ និងអនុសាសន៍ដ៏ខ្ពង់ខ្ពស់ ដើម្បីជាតម្រង់ទិសការងារទៅមុខទៀត ។

ជាទីបញ្ចប់នេះ ក្នុងនាម លេខាធិការដ្ឋាននៃ គណៈ កម្មាធិការជាតិ ប.ជ.រ.ព.ភ ក្រុមការងារទេសន្តរប្រវេសន៍ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការដៃគូដែលបានចូលរួមឧបត្ថម្ភគាំទ្រទាំងថវិកាទាំងស្មារតី កម្លាំងកាយចិត្ត ដើម្បីចូលរួមជាមួយរាជរដ្ឋាភិបាល ក្នុងការធ្វើឲ្យសិក្ខាសាលនេះប្រព្រឹត្តទៅបានដោយជោគជ័យ ។ សូមគោរពថ្លែងអំណរគុណ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានចូលរួមយ៉ាងសកម្មក្នុងសិក្ខាសាលានេះ និងសូមគោរពជូនពរ សុខភាពល្អ និងជោគជ័យគ្រប់ភារកិច្ច ៕

រាជធានីភ្នំពេញ ថ្ងៃ ទី ២៨ ខែ មិនា ឆ្នាំ ២០១៣

ប្រធានលេខាធិការដ្ឋានប.ជ.រ.ព.ភ